គជអប
NCDD

លេខាធិការដ្ឋាន
គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# គោលការណ៍ណែនាំ
# ស្តីពី
# ការគ្រប់គ្រងហានិភ័យលើបរិស្ថាន និងសង្គមសម្រាប់ការអនុវត្តគម្រោង ក្នុងក្របខណ្ឌកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ

ខែសីហា ឆ្នាំ២០១៩

## មាតិកា


១. សេចក្តីផ្តើម ........ 1

២. ប្រភេទនៃគម្រោង ........ 2

៣. តួនាទី និងការទទួលខុសត្រូវសម្រាប់ការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម ........ 3

៤. ការត្រួតពិនិត្យបរិស្ថាន និងសង្គម ........ 4

ប្រភេទA៖ មានហានិភ័យខ្ពស់ ........ 4

ប្រភេទB ៖ មានហានិភ័យមធ្យម ........ 4

ប្រភេទC ៖ មានហានិភ័យទាប ........ 5

៥. ដំណើរការពិនិត្យបរិស្ថាន និងសង្គម ........ 5

៦. ការរៀបចំផែនការគ្រប់គ្រងហានិភ័យ ........ 8

៦.១. ការវាយតម្លៃផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គម ........ 8

៦.២. ផែនការការពារបរិស្ថាន និងសង្គម ........ 8

៧. ការរៀបចំវិធានការបន្ធូរបន្ថយ ........ 9

៧.១. យុទ្ធសាស្ត្រទី២៖ ពលកម្ម និងលក្ខខណ្ឌការងារ ........ 9

៧.២. យុទ្ធសាស្ត្រទី៣៖ ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងការបំពុលបរិស្ថាន ........ 10

៧.៣. យុទ្ធសាស្ត្រទី៤៖ សុខភាព សុវត្ថិភាព និងសុខុមាលភាពសហគមន៍ ........ 11

៧.៤. យុទ្ធសាស្ត្រទី៥៖ លទ្ធកម្មដីធ្លី និងការតាំងលំនៅដោយមិនស្ម័គ្រចិត្ត ........ 11

៧.៥. យុទ្ធសាស្ត្រទី៦៖ ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតប្រកបដោយចីរភាព ........ 11

៧.៦. យុទ្ធសាស្ត្រទី៧៖ ជនជាតិដើមភាគតិច ........ 11

៧.៧. យុទ្ធសាស្ត្រទី៨៖ បេតិកភណ្ឌវប្បធម៌ ........ 11

៨. ការផ្សព្វផ្សាយផែនការគ្រប់គ្រងបរិស្ថាន និងការការពារសង្គម ........ 12

៩. ការអនុវត្ត ផែនការគ្រប់គ្រងបរិស្ថាន និងការការពារសង្គម ........ 12

១០. ការតាមដានត្រួតពិនិត្យ ........ 13

១១. ការរៀបចំចងក្រងមេរៀនបទពិសោធន៍ និងចំណេះដឹងផ្សេងៗ ....................................15
១.២. យន្តការដោះស្រាយបណ្តឹងតវ៉ា និងសំណាងផ្សេងៗ......................................................15
ឧបសម្ព័ន្ធទី១៖ បញ្ជីផ្ទៀងផ្ទាត់ហានិភ័យបរិស្ថាន និងសង្គម...............................................17
ឧបសម្ព័ន្ធ២៖ ផែនការគ្រប់គ្រងផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គម ..................................31

## ១. សេចក្តីផ្តើម

គោលការណ៍ណែនាំនេះគឺជាឧបសម្ព័ន្ធទី២ នៃគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ គោលការណ៍ណែនាំនេះជាឯកសារចម្បងដែលបរិយាយអំពីការគ្រប់គ្រងហានិភ័យទៅលើបរិស្ថាន និងសង្គមសម្រាប់ការគ្រប់គ្រងគម្រោង ក្នុងក្របខណ្ឌនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ហានិភ័យទៅលើបរិស្ថាន និងសង្គមគឺជាផលប៉ះពាល់ជាអវិជ្ជមានដែលបង្កឡើងពីគម្រោងវិនិយោគទាំងឡាយណានៅថ្នាក់ក្រោមជាតិ និងត្រូវបានចែងនៅក្នុងយុទ្ធសាស្រ្តទាំង០៨ នៃគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គម ដូចមានខាងក្រោម៖

យុទ្ធសាស្រ្តទី១៖ ការវិភាគ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងហានិភ័យសង្គម
យុទ្ធសាស្រ្តទី២៖ ពលកម្ម និងលក្ខខណ្ឌការងារ
យុទ្ធសាស្រ្តទី៣៖ ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងការបំពុលបរិស្ថាន
យុទ្ធសាស្រ្តទី៤៖ សុខភាព សុវត្ថិភាព និងសុខុមាលភាពសហគមន៍
យុទ្ធសាស្រ្តទី៥៖ លទ្ធកម្មដីធ្លី និងការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត
យុទ្ធសាស្រ្តទី៦៖ ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតប្រកបដោយចីរភាព
យុទ្ធសាស្រ្តទី៧៖ ជនជាតិដើមភាគតិច
យុទ្ធសាស្រ្តទី៨៖ បេតិកភណ្ឌវប្បធម៌

ការគ្រប់គ្រងហានិភ័យលើបរិស្ថាន និងសង្គម ត្រូវអនុវត្តទៅតាមគោលការណ៍ដូចខាងក្រោម៖

- ពិនិត្យលើសំណើគម្រោង ឬសំណើថវិកា ដើម្បីកំណត់នូវភាពដែលអាចកើតមានឡើងលើការបង្កហានិភ័យចំពោះបរិស្ថាន និងសង្គម ដោយបែងចែកជាប្រភេទផ្សេងៗគ្នាដូចជា៖ ប្រភេទ A (ហានិភ័យខ្ពស់) ប្រភេទ B (ហានិភ័យមធ្យម) ឬ ប្រភេទ C (ហានិភ័យទាប)
- វាយតម្លៃផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គម សម្រាប់គម្រោងស្ថិតក្នុងប្រភេទA និងរៀបចំផែនការគ្រប់គ្រងផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គម សម្រាប់គម្រោងស្ថិតក្នុងប្រភេទB
- ផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ នូវព័ត៌មានស្តីពីគម្រោង និងផលប៉ះពាល់របស់គម្រោងមុនពេលដែលគម្រោងត្រូវបានអនុម័ត
- អនុវត្តនូវវិធានការណ៍នានាក្នុងការកាត់បន្ថយនូវផលប៉ះពាល់ជាអវិជ្ជមានទៅលើបរិស្ថាន និងសង្គម ដូចដែលបានចែងនៅក្នុងការវាយតម្លៃផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គម ឬផែនការគ្រប់គ្រងផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គម
- តាមដានត្រួតពិនិត្យជាប្រចាំដើម្បីប្រាកដថាការគ្រប់គ្រងហានិភ័យទៅលើបរិស្ថាន និងសង្គមត្រូវបានអនុវត្តដោយត្រឹមត្រូវ

- សិក្សា និងដកស្រង់នូវបទពិសោធន៍សម្រាប់ពង្រឹងនូវការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គមសម្រាប់គម្រោងក្រោយៗទៀត
- អនុវត្តយន្តការទទួលបណ្តឹង និងដោះស្រាយបណ្តឹង

សម្រាប់គម្រោងទាំងឡាយណាដែលផ្តល់មូលនិធិដល់អនុគម្រោងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងក្របខណ្ឌនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវអនុវត្តទៅតាមប្រព័ន្ធនៃការកសាងផែនការ និងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោង (ភីម) របស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំសង្កាត់។ សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង ត្រូវដាក់បញ្ចូលការគ្រប់គ្រងហានិភ័យទៅលើបរិស្ថាន និងសង្គមនៅកម្រិតអនុគម្រោង។ នីតិវិធីនៃគោលការណ៍ណែនាំនេះសម្រាប់ការគ្រប់គ្រងហានិភ័យទៅលើបរិស្ថាន និងសង្គមនៅក្នុងការអនុវត្តគម្រោង និងការអនុវត្តភីម។ ដំណើរការអនុវត្តការគ្រប់គ្រងហានិភ័យទៅលើបរិស្ថាន និងសង្គមដូចមាននៅក្នុងរូបភាពខាងក្រោម៖




សម្រាប់ការវិនិយោគលើគម្រោង ដែលមានទំហំធំ (ទឹកប្រាក់វិនិយោគលើសពីមួយកោដិរៀល) ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវធ្វើការត្រួតពិនិត្យហានិភ័យ និងការវាយតម្លៃផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គម និងការរៀបចំផែនការគ្រប់គ្រងហានិភ័យ។

## ២. ប្រភេទនៃគម្រោង

លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវប្រើប្រាស់គោលការណ៍ណែនាំនេះសម្រាប់ការគ្រប់គ្រងហានិភ័យទៅលើបរិស្ថាន និងសង្គមទៅតាមប្រភេទគម្រោងដូចខាងក្រោម៖

- គម្រោងដាច់ដោយឡែកស្ថិតក្រោមក្របខណ្ឌនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលផ្តល់មូលនិធិ ឬជំនួយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- គម្រោងដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានតម្លៃវិនិយោគលើសពីមួយកោដិរៀល

គោលការណ៍ណែនាំនេះមិនត្រូវបានអនុវត្តចំពោះករណីដូចខាងក្រោម៖

- គម្រោងទាំងឡាយណាដែលបានអនុវត្តទៅតាមគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងបរិស្ថាន និងសង្គម របស់ដៃគូអភិវឌ្ឍន៍
- គម្រោងទាំងឡាយណាដែលបានអនុវត្តទៅតាមគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងបរិស្ថាន និងសង្គម របស់ក្រសួងស្ថាប័នតំណាងឱ្យ គ.ជ.អ.ប. និងមិនបានទទួលមូលនិធិពីមូលនិធិអាកាសធាតុបៃតង (GCF)។

## ៣. តួនាទី និងការទទួលខុសត្រូវសម្រាប់ការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម

ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវទទួលខុសត្រូវលើដំណើរការអនុវត្តការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម ឱ្យបានហ្មត់ចត់។ តាមរយៈការអនុវត្តសកម្មភាពដូចខាងក្រោម៖

- មន្ត្រីទទួលបន្ទុកសុវត្ថិភាពបរិស្ថាន និងសង្គមនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវធ្វើការពិនិត្យបញ្ជាក់បច្ចេកទេស រៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គម តាមដានត្រួតពិនិត្យ និងគ្រប់គ្រងចំណេះដឹង មេរៀនបទពិសោធន៍
- អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី ឬក៏អង្គភាពផ្សេងៗទៀតចំណុះលេខាធិការដ្ឋាន គ.ជ.អ.ប. (ឬស្ថាប័នផ្សេងទៀតនៃកម្មវិធីជាតិ) ទទួលខុសត្រូវក្នុងការកសាងគម្រោង និងអនុវត្តគម្រោង
- រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានទទួលមូលនិធិពីគម្រោង។

គោលការណ៍ណែនាំនេះបានបង្ហាញនូវដំណើរការនៃការគ្រប់គ្រងហានិភ័យទៅលើបរិស្ថាន និងសង្គម ដែលមានលក្ខណៈសាមញ្ញសម្រាប់អ្នកអនុវត្ត ហើយក៏បានបង្ហាញនូវគោលបំណងនៃការរៀបចំឱ្យមានសុវត្ថិភាពបរិស្ថាន និងសង្គម និងគោលការណ៍សំខាន់ៗនៃគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ដើម្បីអនុវត្តគោលនយោបាយនេះមន្ត្រីសុវត្ថិភាពបរិស្ថាន និងសង្គម ត្រូវយល់ឱ្យបានច្បាស់លាស់អំពីនីតិវិធីនៃកិច្ចការពារបរិស្ថាន និងសង្គម និងគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ហើយក៏ត្រូវស្វែងយល់ផងដែរនូវគោលនយោបាយ ក្របខណ្ឌគតិយុត្តិពាក់ព័ន្ធនានា ព្រមទាំងតម្រូវការរបស់ដៃគូអភិវឌ្ឍដូចជាមូលនិធិអាកាសធាតុបៃតង (GCF)ជាដើម។ ដោយឡែកមន្ត្រីសុវត្ថិភាពបរិស្ថាន និងសង្គម ត្រូវស្វែងយល់នូវឯកសារមួយចំនួនដូចខាងក្រោម៖

- **Environmental and Social Safeguards at the Green Climate Fund** http://www.gcfreadinessprogramme.org/sites/default/files/Environmental%20and%20Social%20Safeguards%20at%20the%20Green%20Climate%20Fund.pdf
- **IFC Performance Standards on Environmental and Social Sustainability**; https://www.ifc.org/wps/wcm/connect/c8f524004a73daeca09afdf998895a12/IFC_Performance_Standards.pdf?MOD=AJPERES
- **Green Climate Fund Indigenous People Policy (IPP)**: https://www.greenclimate.fund/documents/20182/953917/GCF_B.19_05_-_GCF_Indigenous_Peoples_Policy.pdf/cebd8ee3-c175-4f35-b847-e0a7cbf3e1dc

មន្ត្រីសុវត្ថិភាពបរិស្ថាន និងសង្គម ត្រូវទទួលខុសត្រូវក្នុងការផ្តល់ការបណ្តុះបណ្តាលបន្តដល់មន្ត្រីគម្រោងផ្សេងទៀត និងរដ្ឋបាលថ្នាក់ក្រោមជាតិនូវគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គម។

## ៤. ការត្រួតពិនិត្យបរិស្ថាន និងសង្គម

ការត្រួតពិនិត្យគឺជាដំណើរការនៃការកំណត់នូវហានិភ័យ ផលប៉ះពាល់ជាអវិជ្ជមានទៅលើបរិស្ថាន និងសង្គម ដែលអាចបង្កឡើងពីអនុវត្តគម្រោង។ នៅក្នុងករណីខ្លះការត្រួតពិនិត្យលើភាពបរិស្ថាន និងសង្គមអាចអនុវត្តបន្ទាប់ពីការរចនាគម្រោងពោលគឺសេចក្តីព្រាងគម្រោង ប៉ុន្តែត្រូវអនុវត្តមុនពេលអនុម័តគម្រោងជាចាំបាច់។

ដោយផ្អែកលទ្ធផលនៃការត្រួតពិនិត្យបរិស្ថាន និងសង្គម គម្រោងត្រូវបានចាត់ថ្នាក់ទៅក្នុងប្រភេទបីផ្សេងៗគ្នា ដូចខាងក្រោម៖

### ប្រភេទA៖ មានហានិភ័យខ្ពស់

ប្រភេទA គម្រោងមានហានិភ័យខ្ពស់ គឺជាគម្រោងដែលអាចបង្កហានិភ័យ និងផលប៉ះពាល់ជាអវិជ្ជមានក្នុងកម្រិតខ្ពស់ និងរយៈពេលយូរចំពោះបរិស្ថាន និងសង្គម។ ហានិភ័យ និងផលប៉ះពាល់ជាអវិជ្ជមានទាំងនោះអាចកើតមានឡើងអាស្រ័យទៅតាមប្រភេទសកម្មភាពនៃគម្រោង (ឧទាហរណ៍៖ ការសាងសង់ទំនប់កាត់ទន្លេ) ឬការអនុវត្តសកម្មភាពទាំងឡាយណាដែលស្ថិតលើទីតាំងការពារ (ឧទាហរណ៍៖ ដែនជំរកសត្វព្រៃ ឬក៏ស្ថានីយបេតិកភណ្ឌវប្បធម៌ជាដើម)។

> **មូលនិធិអាកាសធាតុបៃតងបានកំណត់ប្រភេទA (មានហានិភ័យខ្ពស់) គឺជា "សកម្មភាពដែលអាចបង្កឱ្យមានហានិភ័យ ឬផលប៉ះពាល់ជាអវិជ្ជមានទៅលើបរិស្ថាន និងសង្គម ដែលហានិភ័យ និងផលប៉ះពាល់ទាំងនោះមិនអាចត្រលប់ទៅរកសភាពដើមវិញ ឬក៏មិនដែលធ្លាប់កើតមានឡើង"។**
>
> ប្រភព៖ សុវត្ថិភាពបរិស្ថាន និងសង្គម របស់មូលនិធិអាកាសធាតុបៃតង

គម្រោងដែលមានហានិភ័យខ្ពស់ចាំបាច់ត្រូវធ្វើការវិភាគយ៉ាងល្អិតល្អន់ផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គម ដោយអ្នកជំនាញការ។ ដៃគូអភិវឌ្ឍខ្លះ ដូចជាGCF ប្រហែលជាមិនអនុញ្ញាតិឱ្យប្រើប្រាស់មូលនិធិសម្រាប់គម្រោងដែលស្ថិតនៅក្នុងប្រភេទA ដែលបង្កហានិភ័យខ្ពស់នោះទេ។

### ប្រភេទB ៖ មានហានិភ័យមធ្យម

ប្រភេទB គម្រោងមានហានិភ័យមធ្យម គឺជាគម្រោងដែលអាចបង្កឱ្យមានហានិភ័យ និងផលប៉ះពាល់ជាអវិជ្ជមានទៅលើបរិស្ថាន និងសង្គម ដែលផលប៉ះពាល់ទាំងនោះមានទំហំតូច ប៉ះពាល់ទៅលើមនុស្សចំនួនតិច ប៉ះពាល់លើផ្ទៃដីទំហំតូច និងមិនបង្កផលប៉ះពាល់រយៈពេលយូរ។ ហើយក៏មិនបង្កឱ្យមានផលប៉ះពាល់នៅលើទីតាំងការពារ (ឧទាហរណ៍៖ ដែលជំរកសត្វព្រៃ ឬស្ថានីយបេតិកភ័ណ្ឌវប្បធម៌)។

> មូលនិធិអាកាសធាតុបៃតងបានកំណត់ប្រភេទB (មានហានិភ័យមធ្យម) គឺជា “សកម្មភាពដែលអាចបង្កឱ្យមានហានិភ័យ ឬផលប៉ះពាល់ជាអវិជ្ជមានទៅលើបរិស្ថាន និងសង្គម ដែលហានិភ័យ និងផលប៉ះពាល់ទាំងនោះមានទំហំតូច ប៉ះពាល់លើតំបន់ជាក់លាក់ អាចត្រលប់ទៅរកសភាពដើមវិញភាគច្រើន និងអាចកាត់បន្ថយផលប៉ះពាល់បានតាមរយៈវិធានការកាត់បន្ថយផលប៉ះពាល់”។
>
> ប្រភព៖ សុវត្ថិភាពបរិស្ថាន និងសង្គម របស់មូលនិធិអាកាសធាតុបៃតង

ប្រសិនបើគម្រោងស្ថិតក្នុងប្រភេទB ត្រូវរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គម។ ផែនការគ្រប់គ្រងបរិស្ថាន និងសង្គមត្រូវកំណត់ហានិភ័យជាក់លាក់ពាក់ព័ន្ធនឹងគម្រោង និងវិធានការនានាដែលនឹងត្រូវអនុវត្តដើម្បីកាត់បន្ថយហានិភ័យ ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន។

សម្រាប់គម្រោងដែលនឹងផ្តល់មូលនិធិដល់រដ្ឋបាលថ្នាក់ក្រោមជាតិ លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវប្រើប្រាស់ផែនការគ្រប់គ្រងបរិស្ថាន និងសង្គមជាគោលការណ៍សម្រាប់ការត្រួតពិនិត្យសុវត្ថិភាព និងការគ្រប់គ្រងហានិភ័យនៅកម្រិតអនុគម្រោង អនុលោមទៅតាមសៀវភៅណែនាំស្តីពីការអនុវត្តគម្រោង។

### ប្រភេទC ៖ មានហានិភ័យទាប

ប្រភេទC គម្រោងមានហានិភ័យទាប គឺជាគម្រោងដែលមិនមានបង្កផលប៉ះពាល់ជាអវិជ្ជមានទៅលើបរិស្ថាន និងសង្គម។ សម្រាប់គម្រោងប្រភេទនេះ មិនចាំបាច់ត្រូវរៀបចំផែនការគ្រប់គ្រងហានិភ័យនោះទេ។

> មូលនិធិអាកាសធាតុបៃតងបានកំណត់ប្រភេទC (មានហានិភ័យទាប) គឺជា “សកម្មភាពដែលបង្កហានិភ័យ និង ឬផលប៉ះពាល់តិចតួច ឬក៏គ្មាន ទៅលើបរិស្ថាន ឬសង្គម”។
>
> ប្រភព៖ សុវត្ថិភាពបរិស្ថាន និងសង្គម របស់មូលនិធិអាកាសធាតុបៃតង

## ៥. ដំណើរការពិនិត្យបរិស្ថាន និងសង្គម

ការត្រួតពិនិត្យបរិស្ថាន និងសង្គម ត្រូវធ្វើឡើងដោយមន្ត្រីសុវត្ថិភាពបរិស្ថាន និងសង្គម ប្រចាំនៅលេខាធិការដ្ឋាន គ.ជ.អ.ប. ដោយប្រើប្រាស់បញ្ជីត្រួតពិនិត្យសុវត្ថិភាពបរិស្ថាន និងសង្គមដែលមានភ្ជាប់ក្នុងគោលការណ៍ណែនាំនេះ។

ដើម្បីធ្វើការពិនិត្យមន្ត្រីសុវត្ថិភាពបរិស្ថាន និងសង្គម ត្រូវស្វែងយល់ឱ្យបានជាក់លាក់នូវគោលការណ៍សំខាន់ៗដូចខាងក្រោម៖

- ប្រភេទនៃអនុគម្រោងដែលត្រូវផ្តល់មូលនិធិគាំទ្រដោយគម្រោង
- ទំហំនៃអនុគម្រោង
- ទីតាំងនៃអនុគម្រោង

- ប្រភេទនៃអ្នកដែលអាចទទួលរងផលប៉ះពាល់ពីអនុគម្រោង ជាពិសេសក្រុមជនងាយរងគ្រោះដូចជាជនជាតិដើមភាគតិច

គម្រោងដែលស្ថិតក្រោមក្របខណ្ឌ នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលផ្តល់មូលនិធិដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ចំពោះគម្រោងប្រភេទនេះសកម្មភាពលំអិត និងទីតាំងគម្រោង នឹងប្រហែលជាមិនត្រូវបានគេដឹងបាននៅក្រោយពេលដែលការត្រួតពិនិត្យកិច្ចការពារបរិស្ថាន និងសង្គម។ ដូច្នេះការពិនិត្យត្រូវធ្វើឡើងដោយផ្អែកលើ៖

- ព័ត៌មានទូទៅអំពីប្រភេទនៃអនុគម្រោងដែលអាចទទួលបានការគាំទ្រ
- បញ្ជីវិនិយោគដែលមានលក្ខណៈសមស្រប
- បញ្ជីវិនិយោគដែលមានលក្ខណៈមិនសមស្របនឹងទទួលបានការគាំទ្រ
- តំបន់គោលដៅរបស់គម្រោង

គម្រោងដែលអាចទទួលយកបានសម្រាប់គម្រោងបានរចនា ដោយរួមបញ្ចូលបញ្ជីវិនិយោគមានលក្ខណៈមិនសមស្របនឹងទទួលបានការគាំទ្រ បើមិនដូច្នេះទេគម្រោងនឹងត្រូវចាត់បញ្ចូលទៅក្នុងប្រភេទA។ ឧទាហរណ៍៖ ផ្អែកតាមបញ្ជីត្រួតពិនិត្យបរិស្ថាន និងសង្គម គម្រោងដែលកសាងទំនប់ដែលមានកម្ពស់ខ្ពស់ជាង១៥ម៉ែត្រ ឬក៏ប្រវែងវែងជាង៥០០ម៉ែត្រ អាចកំណត់ចូលក្នុងប្រភេទA។ ដូចនេះក្នុងបញ្ជីវិនិយោគដែលមានលក្ខណៈមិនសមស្របអាចនឹងកំណត់ថាការវិនិយោគលើទំនប់ដែលមានកម្ពស់ខ្ពស់ជាង១៥ម៉ែត្រ ឬក៏មានប្រវែងវែងជាង៥០០ម៉ែត្រ មិនត្រូវបានអនុញ្ញាតឡើយ។

បញ្ជីត្រួតពិនិត្យបរិស្ថាន និងសង្គមរៀបចំឡើងដោយផ្អែកលើយុទ្ធសាស្ត្រទាំង៨ នៃគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ជាទូទៅសំនួរនៅក្នុងបញ្ជីពិនិត្យផ្តោតទៅលើប្រភេទនៃអនុគម្រោង និងទីតាំងអនុវត្តអនុគម្រោង ដែលមានចែងនៅក្នុងយុទ្ធសាស្ត្រទី១ ស្តីពីការវិភាគការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងហានិភ័យសង្គម។

យុទ្ធសាស្ត្រនីមួយៗមានសំនួរផ្សេងៗគ្នា ដែលចំលើយអាចជា "មានហានិភ័យទាប" "មានហានិភ័យមធ្យម" ឬ "មានហានិភ័យខ្ពស់"។ ចំណាត់ថ្នាក់នៃហានិភ័យនឹងត្រូវបង្ហាញនៅក្នុងបញ្ជីត្រួតពិនិត្យបរិស្ថាន និងសង្គម។

ឧទាហរណ៍៖ សំនួរទី ១.៤ "តើគម្រោងមានសាងសង់ថ្មី ឬក៏ជួសជុលប្រព័ន្ធធារាសាស្ត្រដែរឬទេ?"

- បើសិនជាចំលើយ "គ្មាន" ដូចនេះគម្រោងត្រូវបានកំណត់ថា "មានហានិភ័យទាប" សម្រាប់សំនួរ ១.៤
- បើសិនជាចំលើយ "មាន" គម្រោងមានទំហំអតិបរមាតិចជាង១០០ហិចតា ត្រូវបានកំណត់ថា "មានហានិភ័យមធ្យម" សម្រាប់សំនួរ ១.៤
- បើសិនជាចំលើយ "មាន" គម្រោងមានទំហំធំជាង១០០ហិចតា ត្រូវបានកំណត់ថា "មានហានិភ័យខ្ពស់" សម្រាប់សំនួរ ១.៤។

សំនួរនៅក្នុងបញ្ជីត្រួតពិនិត្យបរិស្ថាន និងសង្គម គឺជាគោលការណ៍សម្រាប់មន្ត្រីសុវត្ថិភាពបរិស្ថាន និងសង្គមដែលត្រូវកំណត់លើផលប៉ះពាល់ជាអវិជ្ជមានដែលអាចនឹងមានឡើង។

តើអ្វីខ្លះជាផលប៉ះពាល់ចម្បងៗ?

- លទ្ធភាពដែលអាចកើតឡើង៖ តើផលប៉ះពាល់ជាអវិជ្ជមានអាចកើតឡើងយ៉ាងដូចម្តេច?
- ភាពញឹកញាប់៖ តើអនុគម្រោងអាចបង្កឱ្យមានហានិភ័យ ឬក៏ផលប៉ះពាល់ញឹកញាប់ប៉ុណ្ណា?
- ទំហំ៖ តើផលប៉ះពាល់អាចមានក្នុងទំហំប៉ុណ្ណា?
- ភាពអាចគ្រប់គ្រងបាន៖ តើហានិភ័យនឹងត្រូវគ្រប់គ្រងយ៉ាងដូចម្តេច?
- រយៈពេល៖ តើហានិភ័យនឹងមាននៅក្នុងរយៈពេលប៉ុណ្ណា?
- ការត្រលប់មករកសភាពដើម៖ តើផលប៉ះពាល់នោះអាចស្តារឡើងវិញបានរទេ? បើបានត្រូវចំណាយពេលយូរប៉ុណ្ណា?

ប្រភព៖ សុវត្ថិភាពបរិស្ថាន និងសង្គម របស់មូលនិធិអាកាសធាតុបៃតង

នីតិវិធីក្នុងការត្រួតពិនិត្យបរិស្ថាន និងសង្គមមានដូចខាងក្រោម៖

១. មន្ត្រីសុវត្ថិភាពបរិស្ថាន និងសង្គម យ៉ាងហោចណាស់មានចំនួន២នាក់ ត្រូវធ្វើការពិនិត្យយ៉ាងហ្មត់ចត់លើឯកសារគម្រោង ដោយរួមបញ្ចូលទាំងវិសាលភាពនៃអនុគម្រោង លក្ខណៈសមស្របនឹងទទួលបានហិរញ្ញប្បទាន ទីតាំង និងអ្នកទទួលផល។

២. មន្ត្រីសុវត្ថិភាព និងសង្គម ត្រូវឆ្លើយគ្រប់សំនួរដែលមាននៅក្នុងបញ្ជីត្រួតពិនិត្យបរិស្ថាន និងសង្គម។

៣. បើសិនជាមន្ត្រីសុវត្ថិភាពបរិស្ថាន និងសង្គម មិនប្រាកដក្នុងការឆ្លើយនឹងសំនួរនោះទេ ត្រូវបញ្ជាក់ជាមួយក្រុមអ្នករចនាគម្រោង។

៤. ក្នុងករណីដែលមន្ត្រីសុវត្ថិភាពបរិស្ថាន និងសង្គមអាចបន្ថែមកំណត់សម្គាល់ទៅក្នុងបញ្ជីត្រួតពិនិត្យបរិស្ថាន និងសង្គម ដោយបញ្ជាក់ពីប្រភេទនៃអនុគម្រោងដែលមិនអនុញ្ញាត។ ឧទាហរណ៍៖ បើគម្រោងស្ថិតក្នុង "មានហានិភ័យមធ្យម" ដែលបានកំណត់ក្នុងសំនួរ ១.៤ (ពីខាងលើ) មន្ត្រីសុវត្ថិភាពបរិស្ថាន និងសង្គម អាចកំណត់សម្គាល់ថា "ទំហំប្រព័ន្ធធំជាង១០០ហិចតាមិនអនុញ្ញាត"។ កំណត់សម្គាល់ទាំងនោះនឹងត្រូវលើកឡើងនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន និងសង្គម។

៥. នៅពេលដែលមន្ត្រីសុវត្ថិភាពបរិស្ថាន និងសង្គម ត្រូវបំពេញបញ្ជីត្រួតពិនិត្យបរិស្ថាន និងសង្គម ដោយកំណត់គម្រោងទៅតាមប្រភេទដូចខងក្រោម៖

   ក. បើសិនជាមានចម្លើយមួយនៅក្នុងបញ្ជីត្រួតពិនិត្យបរិស្ថាន និងសង្គម ជា "ហានិភ័យខ្ពស់" គម្រោងនឹងត្រូវកំណត់ក្នុង "ប្រភេទA៖ មានហានិភ័យខ្ពស់"

ខ. បើសិនជាមិនមានចម្លើយណាមួយនៅក្នុងបញ្ជីត្រួតពិនិត្យបរិស្ថាន និងសង្គម ជា "ហានិភ័យខ្ពស់" ប៉ុន្តែមានចម្លើយមួយនៅក្នុងបញ្ជីជា "ហានិភ័យមធ្យម" គម្រោងនឹងត្រូវកំណត់ក្នុង "ប្រភេទB៖ មានហានិភ័យមធ្យម"

គ. បើសិនជាចម្លើយទាំងអស់នៅក្នុងបញ្ជីត្រួតពិនិត្យបរិស្ថាន និងសង្គម ជា"ហានិភ័យទាប" គម្រោងនឹងត្រូវកំណត់ក្នុង "ប្រភេទC៖ មានហានិភ័យទាប"

៦. មន្ត្រីសុវត្ថិភាពបរិស្ថាន និងសង្គម ត្រូវពិនិត្យលើលទ្ធផលនៃការត្រួតពិនិត្យជាមួយក្រុមរចនាគម្រោង។ ក្នុងករណីដែលក្រុមរចនាគម្រោងសម្រេចធ្វើការកែសម្រួលគម្រោង ប្រភេទហានិភ័យនៃគម្រោងអាចប្តូរពីប្រភេទ A ទៅជាប្រភេទB ឬក៏ពីប្រភេទB ទៅជាប្រភេទC។

## ៦. ការរៀបចំផែនការគ្រប់គ្រងហានិភ័យ

### ៦.១. ការវាយតម្លៃផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គម

បើសិនជាគម្រោងត្រូវបានចាត់ថ្នាក់ក្នុងប្រភេទA (មានហានិភ័យខ្ពស់) ចាំបាច់ត្រូវធ្វើការវាយតម្លៃផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គម។ ការធ្វើការវាយតម្លៃផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គមពេញលេញត្រូវធ្វើឡើងដោយអ្នកជំនាញការ។ ក្រសួងបរិស្ថាន រៀបចំគោលការណ៍ណែនាំស្តីពីការវាយតម្លៃផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គមនៅប្រទេសកម្ពុជា។ អ្នកជំនាញការត្រូវរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គមលំអិតសម្រាប់គម្រោង។ ការវាយតម្លៃផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គមសម្រាប់កម្រិតគម្រោង មិនបានលើកឡើងក្នុងគោលការណ៍ណែនាំនេះទេ។

### ៦.២. ផែនការការពារបរិស្ថាន និងសង្គម

សម្រាប់គម្រោងទាំងឡាយណាដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទB (មានហានិភ័យមធ្យម) ការរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គម ចាំបាច់ត្រូវរៀបចំឡើងទៅតាមគំរូតារាងដែលមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី២ នៃគោលការណ៍ណែនាំនេះ។ សម្រាប់មូលនិធិអាកាសធាតុបៃតង ឬក៏ដៃគូអភិវឌ្ឍន៍ផ្សេងទៀត ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម ត្រូវតែពិនិត្យ និងអនុម័តតំណាលគ្នាជាមួយនឹងសំណើគម្រោង។

ការរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គម រៀបចំឡើងក្នុងគោលបំណងដូចខាងក្រោម៖

១. រៀបចំនូវបញ្ជីហានិភ័យទៅលើបរិស្ថាន និងសង្គម ដែលត្រូវបានត្រួតពិនិត្យ (ឧទាហរណ៍៖ បើសិនជាការត្រួតពិនិត្យទៅឃើញថាមានចម្លើយ មានហានិភ័យមធ្យម ត្រូវដាក់បញ្ចូលទៅក្នុងតារាងគម្រោងដែលត្រូវរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គម)

២. ហានិភ័យនីមួយៗត្រូវផ្សារភ្ជាប់ជាមួយវិធានការបន្ធូរបន្ថយហានិភ័យ ដែលមានដូចជា៖

ក. ការដាក់កំហិតលើវិសាលភាពអនុគ្រោងដែលនឹងត្រូវអនុវត្ត

ខ. ការដាក់កំហិតលើទំហំអនុគម្រោងដែលនឹងត្រូវអនុវត្ត

គ. ការដាក់កំហិតលើប្រភេទទីតាំងអនុគម្រោងដែលអាចអនុវត្តបាន

ឃ. ប្រភេទនៃវិធានការបន្ធូរបន្ថយហានិភ័យដើម្បីកាត់បន្ថយផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គម ពីអនុគម្រោងដែលត្រូវបានអនុញ្ញាតឱ្យអនុវត្ត

៣. កំណត់ពេលវេលាជាក់លាក់លើការអនុវត្តវិធានការបន្ធូរបន្ថយ (ឧទាហរណ៍៖ កំឡុងពេលរៀបចំផែនការអនុគម្រោង កំឡុងពេលអនុវត្តអនុគម្រោង ជាដើម)

៤. សូចនាករសំខាន់ៗត្រូវបានកំណត់ និងធ្វើការតាមដានដោយមន្ត្រីសុវត្ថិភាពបរិស្ថាន និងសង្គម ដោយផ្ទៀងផ្ទាត់លើការអនុវត្តទៅតាមផែនការគ្រប់គ្រងបរិស្ថាន និងសង្គម។

## ៧. ការរៀបចំវិធានការបន្ធូរបន្ថយ

ដើម្បីកំណត់វិធានការសមស្របនានាក្នុងការកាត់បន្ថយហានិភ័យ ក្រុមការងារគួរអនុវត្តផ្អែកតាមគោលនយោបាយស្ដីពីសុវត្ថិភាពបរិស្ថាន និងសង្គម ដែលផ្ដល់ការណែនាំសម្រាប់អនុវត្តយុទ្ធសាស្ត្រនីមួយៗនៃយុទ្ធសាស្ត្រទាំង៨។

ការណែនាំផ្សេងៗទៀតលើវិធានការកាត់បន្ថយហានិភ័យ មានបង្ហាញនៅក្នុងឯកសារស្ដីពី «ការការពារបរិស្ថាន និងសង្គមនៃមូលនិធិអាកាសធាតុបៃតង»។

សម្រាប់យុទ្ធសាស្ត្រទី៥៖ លទ្ធកម្មដីធ្លី និងការតាំងលំនៅថ្មីដោយមិនស្ម័គ្រចិត្ត យុទ្ធសាស្ត្រទី៦៖ ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងប្រកបដោយចីរភាពនៃធនធានធម្មជាតិ និងយុទ្ធសាស្ត្រទី៧៖ ជនជាតិដើមភាគតិច គឺមាននីតិវិធីជាក់លាក់សម្រាប់ដំណើរការគ្រប់គ្រងហានិភ័យនានានៅក្នុងសៀវភៅណែនាំ នៃការអនុវត្តគម្រោងមូលនិធិឃុំសង្កាត់ និងនីតិវិធីអនុវត្តគម្រោងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងៗទៀត។ នីតិវិធីទាំងនេះ ត្រឹមត្រូវតាមគោលបំណង និងមានភាពសមស្របចំពោះប្រភេទអនុគម្រោង និងសកម្មភាពនានាដែលបានអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

សៀវភៅណែនាំនៃការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ និងឯកសារផ្សេងទៀតនឹងត្រូវបានធ្វើបច្ចុប្បន្នភាពឡើងវិញ ដើម្បីបញ្ចូលនូវនីតិវិធីនៃវិធានការការពារមួយចំនួន ពាក់ព័ន្ធនឹងយុទ្ធសាស្ត្រនៃគោលនយោបាយស្ដីពីសុវត្ថិភាពបរិស្ថាន និងសង្គម ដែលមិនមានចែងនៅក្នុងឯកសារទាំងនេះនាពេលកន្លងមក។

ចំណុចផ្សេងៗទៀតដែលត្រូវយកចិត្តទុកដាក់នូវវិធានការកាត់បន្ថយហានិភ័យ ពាក់ព័ន្ធនឹងគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ មានរៀបរាប់ដូចខាងក្រោម៖

### ៧.១. យុទ្ធសាស្ត្រទី២៖ ពលកម្ម និងលក្ខខណ្ឌការងារ

រាល់គម្រោង និងសកម្មភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវតែអនុវត្តតាមច្បាប់ស្ដីពីការងាររបស់កម្ពុជា ដោយត្រូវផ្ដល់លក្ខខណ្ឌនានាក្នុងការបំពេញការងារប្រកបដោយសុវត្ថិភាពដល់និយោជិក ហើយត្រូវធានាថាមិនមានការរើសអើងប្រឆាំងនឹងស្ត្រីភេទ ជនជាតិដើមភាគតិច ឬក្រុមណាមួយឡើយ។

ការអនុវត្តទៅតាមច្បាប់ស្តីពីការងារ គួរតែជាលក្ខខណ្ឌស្តង់ដារសម្រាប់រាល់កិច្ចសន្យាក្នុងការអនុវត្តគម្រោង និងសកម្មភាពនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ប្រភេទគម្រោងមួយចំនួនអាចបង្កឱ្យមានគ្រោះថ្នាក់ពេលកំពុងអនុវត្តការងារ។

រាល់គម្រោងសាងសង់ទាំងអស់អាចបង្កឱ្យមានគ្រោះថ្នាក់ ហេតុដូច្នេះរាល់កិច្ចសន្យាសម្រាប់ការសាងសង់ដែលស្ថិតក្នុងគម្រោង និងសកម្មភាពនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គួរតែមានចែងអំពីវិធានការសម្រាប់ធានាសុវត្ថិភាពរបស់កម្មករ និងអ្នកផ្សេងទៀតដែលនៅជិតការដ្ឋានសាងសង់។

គម្រោងខ្លះទៀតអាចបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ (ឧទាហរណ៍ដូចជា ការរំលំអគារចាស់ៗដែលមានប្រើប្រាស់សារធាតុម្យ៉ាងការពារកម្តៅនៅដំបូល) ចាំបាច់ត្រូវមានវិធានការសុវត្ថិភាពជាក់លាក់ (ត្រូវមានឧបករណ៍ដកដង្ហើមមានសុវត្ថិភាព) ត្រូវមានចែងនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន និងសង្គម។

ប្រភេទការងារមួយចំនួននៅក្នុងវិស័យឧស្សាហកម្ម (ឧទាហរណ៍ សិប្បកម្មឡឥដ្ឋ) ដែលភាគច្រើនមានកុមារកំពុងធ្វើការងារនៅទីនោះ បើទោះបីផ្ទុយនឹងច្បាប់ការងាររបស់កម្ពុជាក៏ដោយ។ ប្រសិនបើមានហានិភ័យកើតឡើង គឺត្រូវមានវិធានការជាក់លាក់ ដើម្បីបង្ការកុំឱ្យមានហានិភ័យទាំងនេះកើតឡើង។

ប្រសិនបើគម្រោងនេះត្រូវការកម្មករច្រើន មកពីកន្លែងផ្សេងៗ ហើយត្រូវស្នាក់នៅក្នុងការដ្ឋាន នោះអាចបណ្តាលឱ្យកើតមានបញ្ហាសង្គមដូចជា៖

- ស្ថានភាពកន្លែងស្នាក់នៅខ្វះអនាម័យ
- ការបំពុលដល់ប្រភពទឹកសម្រាប់ប្រជាជនក្នុងមូលដ្ឋាន
- ទំនាស់រវាងប្រជាពលរដ្ឋមូលដ្ឋាន ជាមួយកម្មករមកពីខាងក្រៅ
- ការឆ្លងរាលដាលនៃជម្ងឺអេដស៍ និងជម្ងឺកាមរោគផ្សេងៗទៀត។

វិធានការកាត់បន្ថយអាចរួមមាន៖

- ធ្វើការរៀបចំឱ្យមានកន្លែងស្នាក់នៅស្អាតសមរម្យ និងមានសុវត្ថិភាពសម្រាប់កម្មករ
- ការបណ្តុះបណ្តាលការយល់ដឹងអំពីមេរោគអេដស៍។

៧.២. យុទ្ធសាស្ត្រទី៣៖ ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងការបំពុលបរិស្ថាន

វិធានការបន្ធូរបន្ថយហានិភ័យនៅក្នុងយុទ្ធសាស្ត្រទី៣ រួមមាន៖

- វិធានការដើម្បីកាត់បន្ថយការបំពុលដោយដាក់កម្រិតលើប្រភេទគ្រឿងម៉ាស៊ីនឬសម្ភារៈមួយចំនួន
- វិធានការដើម្បីធានាសំណល់រឹង សំណល់រាវ និងសារធាតុផ្សេងៗត្រូវបានគ្រប់គ្រង និងចាត់ចែងដោយសុវត្ថិភាព
- វិធានការដើម្បីតែបន្ថឹងការប្រើប្រាស់សារធាតុគីមីកសិកម្ម ឬសម្ភារបំពុលដទៃទៀតនៅក្នុងការអនុវត្តគម្រោង។

## ៧.៣. យុទ្ធសាស្ត្រទី៤៖ សុខភាព សុវត្ថិភាព និងសុខុមាលភាពសហគមន៍

ក្នុងករណីជាច្រើន ផលប៉ះពាល់ដល់សុខភាព និងសុវត្ថិភាពនៃការអនុវត្តគម្រោង និងសកម្មភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មានតិចតួច ឬត្រូវបានចែងរួចហើយនៅក្នុងយុទ្ធសាស្ត្រផ្សេងទៀត។ បញ្ហាសំខាន់មួយគឺសុវត្ថិភាពផ្លូវថ្នល់ ដែលគម្រោងផ្លូវថ្នល់អាចបណ្តាលឱ្យមានការបង្កើនចរាចរណ៍ និង/ឬអ្នកបើកបរបើកលឿនជាងមុនដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ ជាពិសេសដោយសារប្រជាជនក្នុងមូលដ្ឋាន មិនធ្លាប់មានចរាចរណ៍មមាញឹកខ្លាំងបែបនេះ។ ហេតុដូច្នេះ គម្រោងគួរតែបញ្ចូលនូវវិធានការបន្ធូរបន្ថយគ្រោះថ្នាក់រួមមាន៖ (១) ការរៀបចំសញ្ញាសុវត្ថិភាពនៅតាមផ្លូវ និង(២) ផ្តល់ការណែនាំអំពីសុវត្ថិភាពចរាចរណ៍ដល់សហគមន៍មូលដ្ឋាន។

## ៧.៤. យុទ្ធសាស្ត្រទី៥៖ លទ្ធកម្មដីធ្លី និងការតាំងលំនៅដោយមិនស្ម័គ្រចិត្ត

ការអនុវត្តបានត្រឹមត្រូវស្របតាមនីតិវិធីណែនាំនៃការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ (ឬរដ្ឋបាលថ្នាក់ក្រោមផ្សេងទៀតដែលពាក់ព័ន្ធ) នឹងធានានូវការអនុវត្តតាមគោលការណ៍នៃគោលនយោបាយសុវត្ថិភាពបរិស្ថាន និងសង្គម។

## ៧.៥. យុទ្ធសាស្ត្រទី៦៖ ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតប្រកបដោយចីរភាព

សកម្មភាពគម្រោងដែលស្ថិតនៅតំបន់ដែលងាយរងគ្រោះ ត្រូវមានការវាយតម្លៃផលប៉ះពាល់បរិស្ថានលើសកម្មភាពទាំងនោះ ដោយអនុវត្តតាមរបៀបដែលសហគមន៍មូលដ្ឋានបានចូលរួម ដែលត្រូវបានចងក្រងនៅក្នុងនីតិវិធីណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ (សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត)។ នីតិវិធីទាំងនេះ ត្រូវបានរៀបចំស្របតាមគោលបំណង និងមានភាពសមស្របចំពោះគម្រោងគាំទ្រដោយធនាគារពិភពលោក និងដៃគូអភិវឌ្ឍន៍អន្តរជាតិនានា។

## ៧.៦. យុទ្ធសាស្ត្រទី៧៖ ជនជាតិដើមភាគតិច

សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ មាននីតិវិធីណែនាំជាក់លាក់ជាច្រើន ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ជនជាតិភាគតិចដែលរងផលប៉ះពាល់ដោយការអនុវត្តគម្រោង ដោយផ្អែកលើគោលការណ៍នៃ "ការព្រមព្រៀងដោយគ្មានការបង្ខិតបង្ខំនិងមានភាពជាក់លាក់" តាមរយៈការពិគ្រោះយោបល់ជាមួយតំណាងជនជាតិដើមភាគតិច ដែលត្រូវបានជ្រើសរើសផ្ទាល់ដោយសហគមន៍។ សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ និងគោលការណ៍ណែនាំប្រហាក់ប្រហែលគ្នាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត គួរមានការពិនិត្យមើលឡើងវិញដើម្បីធានាឱ្យមានសង្គតិភាពជាមួយគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គម ព្រមទាំងជាមួយច្បាប់ និងបទដ្ឋានគតិយុត្តជាធរមានរបស់កម្ពុជា។

## ៧.៧. យុទ្ធសាស្ត្រទី៨៖ បេតិកភណ្ឌវប្បធម៌

រហូតមកទល់បច្ចុប្បន្ន ការការពារបេតិកភ័ណ្ឌវប្បធម៌មិនបានបញ្ជាក់ច្បាស់លាស់នៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឡើយ។ ជាធម្មតា គម្រោងមិនគួរអនុវត្តនៅតំបន់ដែលមានផលប៉ះពាល់ដល់បេតិកភ័ណ្ឌវប្បធម៌រូបវន្ត (ឧ. ដូចជាប្រាសាទបុរាណជាដើម)។ ប្រសិនបើមានហានិភ័យកើតឡើងនៅតំបន់ប្រាសាទបុរាណ នោះនឹងបង្កឱ្យមានផលប៉ះពាល់មិនខាន ហេតុនេះមន្ទីរវប្បធម៌ខេត្ត គួរចូលរួមផ្តល់យោបល់ណែនាំអំពីបញ្ហានេះ។ ចំពោះបេតិកភ័ណ្ឌវប្បធម៌ដែលមានសារៈសំខាន់ចំពោះសហគមន៍មូលដ្ឋាន នោះផែនការគ្រប់គ្រង

ហានិភ័យ ត្រូវមានការចូលរួមរៀបចំដោយសហគមន៍ ដែលប្រហាក់ប្រហែលគ្នានឹងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ក្នុងការគ្រប់គ្រងបរិស្ថាន។

## ៨. ការផ្សព្វផ្សាយផែនការគ្រប់គ្រងបរិស្ថាន និងការការពារសង្គម

ផែនការគ្រប់គ្រងបរិស្ថាន និងការការពារសង្គម ត្រូវមានការអនុម័តពីប្រធានលេខាធិការដ្ឋានគ.ជ.អ.ប. ឬដោយប្រធានអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី។ បន្ទាប់មកឯកសាររៀបចំគម្រោង និងផែនការគ្រប់គ្រងបរិស្ថាន និងសង្គម ត្រូវតែដាក់នៅលើគេហទំព័ររបស់លេខាធិការដ្ឋានគ.ជ.អ.ប។ គោលបំណងគឺដើម្បីឱ្យអ្នកពាក់ព័ន្ធនានាទទួលបានព័ត៌មានជាក់លាក់អំពីគម្រោង និងហានិភ័យនានាដែលអាចកើតឡើង។ ដៃគូអភិវឌ្ឍន៍មួយចំនួនរួមទាំងមូលនិធិអាកាលធាតុបៃតង តម្រូវឱ្យមានផ្សព្វផ្សាយនូវផែនការគ្រប់គ្រងបរិស្ថាន និងសង្គមក្នុងរយៈពេលកំណត់ណាមួយមុនពេលដាក់ជូននូវសំណើគម្រោងដើម្បីអនុម័ត។ ចំពោះមូលនិធិអាកាសធាតុបៃតង នីតិវិធីតម្រូវឱ្យមានការផ្សព្វផ្សាយរយៈពេល៣០ថ្ងៃ មុនពេលការប្រជុំសម្រេចរបស់ក្រុមប្រឹក្សាភិបាលមូលនិធិអាកាសធាតុបៃតង។

## ៩. ការអនុវត្ត ផែនការគ្រប់គ្រងបរិស្ថាន និងការការពារសង្គម

គោលការណ៍រួម រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវក្នុងការអនុវត្តតាមគោលនយោបាយសុវត្ថិភាពបរិស្ថាននិងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការអនុវុត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមានរបស់កម្ពុជា។ ចំពោះគម្រោង និងសកម្មភាពតូចៗភាគច្រើន ត្រូវជានាឱ្យមានការអនុវុត្តដូចខាងក្រោម៖

- អនុវត្តតាមនីតិវិធីដែលមានចែងនៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោង (ឧទាហរណ៍ដូចជាសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់-PIM)
- ជៀសវាងប្រភេទសកម្មភាពណាដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដូចដែលបានកំណត់ក្នុងផែនការគ្រប់គ្រងបរិស្ថាន និងការការពារសង្គម
- ក្នុងករណីដែលសកម្មភាពគម្រោងបញ្ជាក់ថាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ប៉ុន្តែអាចបង្កឱ្យមានហានិភ័យ ហើយដែលមិនមានចែងលម្អិតច្បាស់លាស់នៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ នោះត្រូវមានការកំណត់ឱ្យបានជាក់លាក់អំពីវិធានការកាត់បន្ថយហានិភ័យនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន និងការការពារសង្គម ។

ដំណាក់កាលដំបូងនៃការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន និងការការពារសង្គម គឺសម្រាប់ក្រុមការងារអនុវត្តគម្រោង ដែលត្រូវពិនិត្យមើលឡើងវិញផែនការនេះហើយត្រូវប្រាកដថាពល់ខ្លឹមសារទាំងអស់ត្រូវបានផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ដែលអាចធ្វើតាមរយៈ៖

- អនុវត្តតាមខ្លឹមសារដែលមានចែងរួចហើយនៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។
- អនុវត្តតាមខ្លឹមសារដែលចែងក្នុងកិច្ចព្រមព្រៀងផ្តល់ជំនួយ សៀវភៅណែនាំនៃការអនុវត្តគម្រោងឬឯកសារផ្សេងទៀតដែលដែលអនុញ្ញាតឱ្យប្រើប្រាស់ និងការអនុវត្តនីតិវិធីសម្រាប់គម្រោង។

- បណ្តុះបណ្តាលបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិតាមតម្រូវការ។

រដ្ឋបាលថ្នាក់ក្រោមជាតិនឹងពិនិត្យមើលសកម្មភាពគម្រោងដែលបានគ្រោងទុក និងកំណត់ថាតើសកម្មភាពណាមួយដែលអាចបង្កឱ្យមានហានិភ័យដល់បរិស្ថាន និងសង្គម។ រដ្ឋបាលថ្នាក់ក្រោមជាតិ អនុវត្តដោយប្រើនីតិវិធីស្តង់ដាកំណត់ជាធរមាន (ដូចសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់) និងនីតិវិធីជាក់លាក់ណាមួយដែលតម្រូវដោយផែនការគ្រប់គ្រងបរិស្ថាន និងការការពារសង្គម ។ ការងារនេះគឺអនុវត្តដូចគម្រោងមូលនិធិឃុំសង្កាត់ ដែលកំពុងអនុវត្តបច្ចុប្បន្ន។ នៅពេលដែលមានហានិភ័យកើតឡើង រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវ៖

- ប្រើប្រាស់ទិន្នន័យគម្រោង (Project Information Database-PID) ដោយមានដាក់កំណត់សម្គាល់ថាជាអនុគម្រោងឬសកម្មភាព ដែលត្រូវមានវិធានការកាត់បន្ថយហានិភ័យ។ ក្រុមការងារទទួលបន្ទុកលើវិធានការការពារសុវត្ថិភាពគម្រោងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងប្រើប្រាស់ព័ត៌មានក្នុងការត្រួតពិនិត្យគម្រោងទាំងនេះ
- ចាត់វិធានការសមស្របក្នុងការកាត់បន្ថយហានិភ័យដែលកើតមានឡើង ដូចជា៖
    - ការរៀបចំផែនការសិក្សាលទ្ធកម្មដីធ្លី
    - រៀបចំផែនការគ្រប់គ្រង និងវាយតម្លៃផលប៉ះពាល់បរិស្ថាន
    - ធានាថាកិច្ចសន្យាសាងសង់ត្រូវមានបញ្ចូលនូវវិធានការសុវត្ថិភាពនានា ដូចជាសុវត្ថិភាពកម្មករផ្តល់ការបណ្តុះបណ្តាលអំពីសុវត្ថិភាពចរាចរណ៍ដល់សហគមន៍មូលដ្ឋានជាដើម។

## ១០. ការតាមដានត្រួតពិនិត្យ

មន្ត្រីទទួលបន្ទុកការងារសុវត្ថិភាពគម្រោងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងទទួលខុសត្រូវក្នុងការតាមដានការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន និងការការពារសង្គម និងការអនុវត្តតាមគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នូវរាល់គម្រោងទាំងអស់នៅក្នុងក្របខ័ណ្ឌនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ លើកលែងតែការរៀបចំដោយឡែកណាមួយតាមតម្រូវការរបស់ដៃគូអភិវឌ្ឍន៍ជាក់លាក់ណាមួយ។ ដូច្នេះរាល់គម្រោងទាំងអស់នៅក្នុងក្របខ័ណ្ឌនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវមានគ្រោងថវិកាសម្រាប់គាំទ្រមន្ត្រីទទួលបន្ទុកការងារសុវត្ថិភាពគម្រោងដើម្បីត្រួតពិនិត្យនៅតាមការដ្ឋានជាក់ស្តែង។

មន្ត្រីទទួលបន្ទុកការងារសុវត្ថិភាពគម្រោង មិនអាចធ្វើការត្រួតពិនិត្យគ្រប់សកម្មភាពទាំងអស់របស់គម្រោងនីមួយៗបានទេ ហេតុនេះការទទួលខុសត្រូវចម្បងគឺមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិអ្នកទទួលបន្ទុក។

មន្ត្រីទទួលបន្ទុកការងារសុវត្ថិភាពគម្រោង នឹងជ្រើសរើសយកគម្រោងណាមួយធ្វើជាឧទាហរណ៍ដោយមានដាក់សញ្ញាសម្គាល់ "ហានិភ័យ" នៅក្នុងទិន្នន័យព័ត៌មានគម្រោង(PID)។ មន្ត្រីទទួលបន្ទុកការងារសុវត្ថិភាពគម្រោង នឹងចុះពិនិត្យគម្រោងផ្ទាល់តាមការជ្រើសរើសដើម្បីផ្ទៀងផ្ទាត់និងធានាថា៖

- នីតិវិធីក្នុងការធានាសុវត្ថិភាពនៃការអនុវត្តគម្រោងត្រូវបានអនុវត្តត្រឹមត្រូវ
- តើមានផលប៉ះពាល់ជាអវិជ្ជមានណាមួយលើបញ្ហាបរិស្ថានឬសង្គមដែរឬទេ

- តើសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធដទៃទៀតមានការពេញចិត្តជាមួយនឹងការអនុវត្តនូវវិធានការធានាសុវត្ថិភាពក្នុងការអនុវត្តដែរឬទេ
- តើមានមេរៀនបទពិសោធន៍អ្វីខ្លះសម្រាប់អនុវត្តគម្រោងនាពេលអនាគត។

ក្នុងករណីដែលមន្ត្រីទទួលបន្ទុកការងារសុវត្ថិភាពគម្រោងរកឃើញថា គោលការណ៍នៃផែនការគ្រប់គ្រងបរិស្ថាន និងសង្គម និងគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមិនបានអនុវត្តបានត្រឹមត្រូវមន្ត្រីនោះគួរអនុវត្តកិច្ចការមួយចំនួនរួមមាន៖

- ការពិនិត្យ អង្កេតរកមូលហេតុដែលបណ្តាលឱ្យមានការអនុវត្តគោលការណ៍នៃផែនការគ្រប់គ្រងបរិស្ថាន និងសង្គម ឬគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមិនបានត្រឹមត្រូវ
- ការពិនិត្យ អង្កេតរកមើលតើមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដែរឬទេ
- ការពិភាក្សាជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងជាមួយអ្នកពាក់ព័ន្ធ ព្រមទាំងផ្តល់យោបល់ដើម្បីកែតម្រូវបញ្ហានេះរួមទាំងការដោះស្រាយចំពោះប្រជាជនដែលរងផលប៉ះពាល់ នៅពេលដែលសមស្រប។

ក្នុងករណីធ្ងន់ធ្ងរមន្ត្រីទទួលបន្ទុកការងារសុវត្ថិភាពគម្រោងអាចស្នើឱ្យ លេខាធិការដ្ឋាន គ.ជ.អ.ប បញ្ឈប់ការផ្តល់ថវិកាដល់រដ្ឋបាលថ្នាក់ក្រោមជាតិ រហូតដល់បញ្ហាទាំងនោះត្រូវបានដោះស្រាយរួច ហើយត្រូវធានាឱ្យមានការអនុវត្តតាមគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងគោលការណ៍នៃផែនការគ្រប់គ្រងបរិស្ថាន និងសង្គមនៅពេលអនាគត។ មន្ត្រីទទួលបន្ទុកការងារសុវត្ថិភាពគម្រោង ត្រូវរៀបចំរបាយការណ៍សង្ខេបប្រចាំត្រីមាស និងប្រចាំឆ្នាំ ដោយបញ្ចូលនូវ៖

- ចំនួន ប្រភេទ និងទីតាំងសកម្មភាពគម្រោងដែលបានចុះត្រួតពិនិត្យ
- ចំនួនគម្រោងដែលបានរកឃើញថា បានអនុវត្តស្របតាមគោលការណ៍នៃផែនការគ្រប់គ្រងបរិស្ថាន និងសង្គម និងគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាននិងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ចំនួនគម្រោងដែលមិនបានអនុវត្តស្របតាមគោលការណ៍នៃផែនការគ្រប់គ្រងបរិស្ថាន និងសង្គម និងគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- វិធានការនានាដែលបានអនុវត្ត ដើម្បីកែតម្រូវចំពោះការមិនអនុវត្តតាមគោលការណ៍នៃផែនការគ្រប់គ្រងបរិស្ថាន និងសង្គម និងគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ត្រូវបញ្ចូលនៅក្នុងរបាយការណ៍ប្រចាំឆ្នាំនូវបញ្ហាទូទៅដែលបានជួបប្រទះនៅក្នុងការអនុវត្ត អនុសាសន៍ និងគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដូចជាការពង្រឹងការអនុវត្តគោលនយោបាយនេះ និងការអនុវត្តសេចក្តីណែនាំនេះតម្រូវឱ្យមានធនធាន ការបណ្តុះបណ្តាល និងវិធានការផ្សេងៗបន្ថែមទៀតតាមតម្រូវការជាក់ស្តែង។

ក្រៅពីការត្រួតពិនិត្យជាទៀងទាត់ដោយមន្ត្រីទទួលបន្ទុកការងារសុវត្ថិភាពគម្រោង ការអនុវត្តគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិគួរមានការពិនិត្យមើល និងកែសម្រួលឡើងវិញដោយការវាយតម្លៃ ឬការធ្វើសវនកម្មពីខាងក្រៅ។ កិច្ចការនេះគឺជាតម្រូវការឱ្យអនុវត្តសម្រាប់គម្រោងដែលផ្តល់ហិរញ្ញវត្ថុដោយគម្រោងមូលនិធិសកល។ ដូច្នេះការធ្វើសវនកម្មពីខាងក្រៅលើការអនុវត្តន៍គោលនយោបាយស្តីពី សុវត្ថិភាពបរិស្ថាន និងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នឹងត្រូវធ្វើឡើងរៀងរាល់បីឆ្នាំម្តង។ វិសាលភាពនៃការធ្វើសវនកម្មពីខាងក្រៅត្រូវរាប់បញ្ចូលទាំងសកម្មភាពនានាដែលផ្តល់ហិរញ្ញប្បទានដោយមូលនិធិអាកាសធាតុបៃតង និងសកម្មភាពនានាផ្តល់ហិរញ្ញប្បទានក្រៅពីមូលនិធិអាកាសធាតុបៃតង ដែលអាស្រ័យទៅតាមការព្រមព្រៀងជាមួយដៃគូជំនួយនានា។

## ១១. ការរៀបចំចងក្រងមេរៀនបទពិសោធន៍ និងចំណេះដឹងផ្សេងៗ

តួនាទីរបស់មន្ត្រីទទួលបន្ទុកការងារសុវត្ថិភាពគម្រោង មានដូចជាការចងក្រង និងផ្សព្វផ្សាយនូវមេរៀនបទពិសោធន៍នៃការអនុវត្តគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដែលរួមចំណែកដល់ការពង្រឹងការអនុវត្តគោលនយោបាយ ព្រមទាំងរួមចំណែកក្នុងការពង្រឹងចំណេះដឹង និងសមត្ថភាពសម្រាប់ការការពារសុវត្ថិភាពផ្នែកបរិស្ថាននិងសង្គមនៅក្នុងប្រទេសកម្ពុជា ជាទូទៅមិនមែនសម្រាប់ការងារក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប៉ុណ្ណោះទេ។

មធ្យោបាយនានាសម្រាប់ចងក្រងមេរៀនបទពិសោធន៍ និងចំណេះដឹងទទួលបានពីការអនុវត្តគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរួមមានដូចជា៖

- របាយការណ៍ប្រចាំឆ្នាំរបស់មន្ត្រីទទួលបន្ទុកការងារសុវត្ថិភាពគម្រោង
- ឯកសារសិក្ខាសាលាពាក់ព័ន្ធនឹងការងារសុវត្ថិភាពគម្រោង
- កិច្ចពិភាក្សាជាមួយស្ថាប័នផ្សេងៗ ពិសេសក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពដែលជាអាជ្ញាធរជាតិទទួលបន្ទុកមូលនិធិសកល។
- របាយការណ៍ករណីសិក្សានានា របាយការណ៍សង្ខេបនៃការរៀបចំគោលនយោបាយ និងឯកសារដទៃទៀតនៅលើគេហទំព័ររបស់ គ.ជ.អ.ប.
- ការរៀបចំ និងផ្សព្វផ្សាយឯកសារបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិស្តីពីការអនុវត្តគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## ១.២. យន្តការដោះស្រាយបណ្តឹងតវ៉ា និងសំណងផ្សេងៗ

គ្រប់អ្នកពាក់ព័ន្ធ រួមទាំងប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយគម្រោង មានសិទ្ធិក្នុងការដាក់ពាក្យបណ្តឹងតវ៉ាអំពីការអនុវត្តន៍នៃវិធានការការពារសុវត្ថិភាពបរិស្ថាននិងសង្គម ដែលរួមមាន៖

- ប្រជាពលរដ្ឋដែលធ្លាប់ជួបប្រទះនូវបទពិសោធន៍រងផលប៉ះពាល់ ឬក៏គិតថាការអនុវត្តគម្រោងនេះអាចមានផលប៉ះពាល់បរិស្ថាន និងសង្គមជាអវិជ្ជមាន

- ប្រជាពលរដ្ឋដែលមិនទទួលរងផលប៉ះពាល់ដោយផ្ទាល់ ប៉ុន្តែមានការព្រួយបារម្ភថាវិធានការការពារសុវត្ថិភាពបរិស្ថាន និងសង្គម អនុវត្តមិនបានត្រឹមត្រូវ

រាល់ពាក្យបណ្តឹងអាចដាក់ទៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលកំពុងអនុវត្តគម្រោង ឬដាក់ផ្ទាល់ទៅលេខាធិការដ្ឋាន គ.ជ.អ.ប. ហើយមិនចាំបាច់តម្រូវឱ្យអ្នកប្តឹងតវ៉ាប្តឹងទៅរដ្ឋបាលថ្នាក់ក្រោមជាតិជាមុនសិនទើបប្តឹងទៅលេខាធិការដ្ឋាន គ.ជ.អ.ប. ពេលក្រោយនោះទេ។ សម្រាប់ដៃគូផ្តល់ជំនួយអន្តរជាតិជាច្រើនរួមទាំងមូលនិធិអាកាសធាតុបៃតង គឺអ្នកពាក់ព័ន្ធអាចដាក់ពាក្យបណ្តឹងតវ៉ាដោយផ្ទាល់ដល់ដៃគូផ្តល់ជំនួយផងដែរ។ ជារួមរាល់ពាក្យបណ្តឹងតវ៉ាត្រូវតែ៖

- កត់ត្រា និងទុកដាក់ជាឯកសារឱ្យបានត្រឹមត្រូវក្នុងការដោះស្រាយសម្រាប់ជាកម្មវត្ថុនៃការធ្វើសវនកម្ម
- មានការស៊ើបអង្កេតឱ្យបានត្រឹមត្រូវដោយឯករាជ្យ របស់ក្រុមអនុវត្តគម្រោង
- អនុញ្ញាតអ្នកប្តឹងតវ៉ាមានសិទ្ធិដឹងអំពីលទ្ធផលនៃការស៊ើបអង្កេត
- ប្រសិនអ្នកប្តឹងតវ៉ា ឬអ្នកដទៃដែលបានបាត់បង់ឬខូចខាតដោយសារផលប៉ះពាល់បរិស្ថាន ឬសង្គមនៃគម្រោង អ្នកទាំងនោះត្រូវតែមានលទ្ធភាពទទួលបានសំណងសមរម្យ។

នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ពាក្យបណ្តឹងតវ៉ាត្រូវតែបានដោះស្រាយតាមរយៈប្រអប់សំបុត្រគណនេយ្យភាព។ នៅលេខាធិការដ្ឋាន គ.ជ.អ.ប. យន្តការសម្រាប់ការដាក់ពាក្យបណ្តឹងតវ៉ាគឺតាមរយៈគេហទំព័ររបស់លេខាធិការដ្ឋាន គ.ជ.អ.ប.។ នីតិវិធីសម្រាប់ដាក់បណ្តឹងតវ៉ា និងការចាត់ចែងបណ្តឹងតវ៉ាគឺធ្វើតាមរយៈគេហទំព័រលេខាធិការដ្ឋាន គ.ជ.អ.ប. ដូចបានរៀបរាប់នៅក្នុងសៀវភៅណែនាំអំពីគោលនយោបាយ និងនីតិវិធីប្រតិបត្តិ។ បណ្តឹងតវ៉ាក៏អាចត្រូវបានបញ្ជូនទៅលេខាធិការដ្ឋាន គ.ជ.អ.ប. ជាលាយលក្ខណ៍អក្សរតាមរយៈទូរស័ព្ទ ឬទៅជួបផ្ទាល់។ ជារួមពាក្យបណ្តឹងតវ៉ាត្រូវតែបានកត់ត្រា និងស៊ើបអង្កេតឱ្យបានត្រឹមត្រូវ។ រាល់ពាក្យបណ្តឹងតវ៉ាទាំងអស់ដែលពាក់ព័ន្ធនឹងសុវត្ថិភាពបរិស្ថាន និងសង្គម មន្ត្រីទទួលបន្ទុកសុវត្ថិភាពបរិស្ថាន និងសង្គម ត្រូវទទួលបានព័ត៌មានគ្រប់គ្រាន់ ហើយត្រូវចូលរួមក្នុងការស៊ើបអង្កេតលើពាក្យបណ្តឹងតវ៉ា លើកលែងតែពាក្យបណ្តឹងតវ៉ាទាំងនោះប្តឹងចំពោះមន្ត្រីទាំងនោះផ្ទាល់៕

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៩

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

លេខាធិការដ្ឋាន

**ទិន្ន ចំរើន**

# ឧបសម្ព័ន្ធទី១៖ បញ្ជីផ្ទៀងផ្ទាត់ហានិភ័យបរិស្ថាន និងសង្គម

## ការគ្រប់គ្រងហានិភ័យផ្នែកបរិស្ថាន និងសង្គម នៃគម្រោងក្នុងក្របខ័ណ្ឌកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

### បញ្ជីសម្រាប់ការត្រួតពិនិត្យគម្រោង និងប្រភេទហានិភ័យ

| | | |
|---|---|---|
| *ឈ្មោះគម្រោង* | | |
| *ប្រភពថវិកាដែលស្នើឡើង* | | |
| *ការពិពណ៌នាសង្ខេបនៃសកម្មភាពគម្រោង៖* | | |
| *តម្លៃប៉ាន់ស្មានរបស់គម្រោង* | | |
| *កាលបរិច្ឆេទចាប់ផ្តើមគម្រោង* | | |
| *កាលបរិច្ឆេទបញ្ចប់គម្រោង* | | |
| *កាលបរិច្ឆេទនៃការត្រួតពិនិត្យ* | | |
| *មន្ត្រីទទួលខុសត្រូវក្នុងការត្រួតពិនិត្យ* | | |
| 1 | *ឈ្មោះ៖* | *តួនាទី៖* |
| 2 | *ឈ្មោះ៖* | *តួនាទី៖* |
| 3 | *ឈ្មោះ៖* | *តួនាទី៖* |
| ***ប្រភេទហានិភ័យផ្នែកបរិស្ថាននិងសង្គមនៃគម្រោងផ្អែកលើការត្រួតពិនិត្យ (A: ហានិភ័យខ្ពស់, B: ហានិភ័យមធ្យមឬ C: ហានិភ័យទាប)*** | | |
| *យោបល់៖* | | |
| *បានអនុម័តដោយ៖* | | |
| *ឈ្មោះ៖* | | *តួនាទី៖* |
| *ហត្ថលេខា៖* | | *កាលបរិច្ឆេទ៖* |

## យុទ្ធសាស្ត្រទី១÷ ការវិភាគ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងហានិភ័យសង្គម

**សំណួរទូទៅសម្រាប់ត្រួតពិនិត្យប្រភេទគម្រោង**

| ល.រ | សំណួរ | មាន/អត់ | ហានិភ័យប្រសិនមាន | កម្រិតហានិភ័យ | មតិយោបល់ |
|---|---|---|---|---|---|
| ១.១ | តើជាគម្រោងសាងសង់ឬជួសជុលទំនប់ដែលមានកម្ពស់ខ្ពស់ជាង១៥ម៉ែត្រឬប្រវែងលើសពី៥០០ម៉ែត្រ? | | ហានិភ័យខ្ពស់ | | |
| ១.២ | តើជាគម្រោងសាងសង់ឬជួសជុលទំនប់ដែលមានកម្ពស់ទាបជាង១៥ម៉ែត្រឬប្រវែងតិចពី៥០០ម៉ែត្រ? | | ហានិភ័យមធ្យម | | |
| ១.៣ | តើជាគម្រោងសាងសង់ឬជួសជុលផ្លូវហាយវេ(ផ្លូវ មានលេខតាមប្រព័ន្ធផ្លូវថ្នល់របស់កម្ពុជា) ឬផ្លូវប្រវែងវែងជាង១០គីឡូម៉ែត្រ? | | ហានិភ័យខ្ពស់ | | |
| ១.៤ | តើជាគម្រោងសាងសង់ឬជួសជុលផ្នែកណាមួយនៃផ្លូវជនបទ (មិនមែនផ្លូវហាយវេនិងមិនមានលេខ) ប្រវែងតិចជាង១០គីឡូម៉ែត្រសម្រាប់អនុគម្រោងមួយ? | | ហានិភ័យមធ្យម | | |
| ១.៥ | តើជាគម្រោងអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រថ្មីសមត្ថភាពលើស៥០០ហ.ត? | | ហានិភ័យខ្ពស់ | | |
| ១.៦ | តើជាគម្រោងប្រព័ន្ធធារាសាស្ត្រខ្នាតតូច (ជាគម្រោងថ្មីសមត្ថភាពតិចជាង៥០០ហ.ត) | | ហានិភ័យមធ្យម | | |
| ១.៧ | តើជាគម្រោងសាងសង់អាគារថ្មីនៅកន្លែងដែលពុំមានអាគារពីមុនទេ? | | ហានិភ័យមធ្យម | | |

## យុទ្ធសាស្ត្រទី២÷ ពលកម្ម និងលក្ខខណ្ឌការងារ

| **ការកាត់បន្ថយហានិភ័យលើកម្លាំងពលកម្ម និងលក្ខខណ្ឌការងារត្រូវយកចិត្តទុកដាក់លើ៖** |
|---|
| ក. ផ្តល់ឱ្យកម្មករនូវព័ត៌មានច្បាស់លាស់និងអាចយល់បានអំពីសិទ្ធិរបស់ពួកគេរួមទាំងការងារដែលទាក់ទងទៅនឹងម៉ោងធ្វើការ ការទូទាត់សំណងនិងអត្ថប្រយោជន៍ផ្សេងៗ។ |
| ខ. ផ្តល់នូវលក្ខខណ្ឌការងារប្រកបដោយសុវត្ថិភាពនិងធានាដល់សុខភាពដោយយកចិត្តទុកដាក់លើហានិភ័យដែលមាននៅក្នុងវិស័យនេះ។ |
| គ. ទប់ស្កាត់ការរើសអើង ប៉ុន្តែបានធានាឱ្យមានការជួល ការទូទាត់សំណង និងការបញ្ឈប់បុគ្គលិក ត្រូវផ្អែកលើគោលការណ៍ស្មើភាពគ្នា និងការប្រព្រឹត្តផ្សេងដោយយុត្តិធម៌។ |

ឃ. មិនបានរារាំងកម្មករមិនឱ្យចូលរួម ឬបង្កើតសមាគម/សហជីពរបស់កម្មករឬធ្វើការចរចាជាសមូហភាពនោះទេ ហើយទប់ស្កាត់កុំឱ្យមានការសងសឹកប្រឆាំងនឹងកម្មករដែលរៀបចំសមាគម/សហជីព។
ង. បង្កើតយន្តការបណ្តឹងតវ៉ាប្រកបដោយប្រសិទ្ធភាពសម្រាប់បុគ្គលិក។
ច. ទប់ស្កាត់មិនឱ្យមានការជួលកុមារ (អាយុក្រោម១៨ឆ្នាំ) តាមរបៀបណាមួយដែលជាការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច ឬបង្កគ្រោះថ្នាក់ដល់សុខភាព ការអប់រំ ឬការអភិវឌ្ឍសង្គមរបស់កុមារ។
ឆ. ទប់ស្កាត់មិនឱ្យប្រើប្រាស់កម្លាំងពលកម្មដោយបង្ខំឬមានការជួញដូរមនុស្ស។
ជ. ខិតខំធានាថាកម្មករដែលមានកិច្ចសន្យាការងារ ត្រូវបានការពារនៅពេលជួលភាគីទីបីណាមួយផ្សេងទៀត។
ឈ. ត្រួតពិនិត្យខ្សែសង្វាក់ផ្គត់ផ្គង់ដើម្បីកំណត់និងកាត់បន្ថយហានិភ័យចំពោះកុមារឬធ្វើការដោយបង្ខំ ឬត្រួតពិនិត្យលើការព្រួយបារម្ភអំពីបញ្ហាសុវត្ថិភាពណាមួយ។

**សំណួរត្រួតពិនិត្យហានិភ័យចំពោះពលកម្ម និងលក្ខខណ្ឌការងារ**

| ល.រ | សំណួរ | មាន/អត់ | ហានិភ័យប្រសិនមាន | កម្រិតហានិភ័យ | មតិយោបល់ |
|---|---|---|---|---|---|
| ២.១ | តើគម្រោងនេះ តម្រូវឱ្យមានជួលជាបណ្តោះអាសន្នឬជាអចិន្ត្រៃយ៍កម្លាំងពលកម្មក្នុងមូលដ្ឋានឬក្នុងតំបន់គម្រោងទេ | | ហានិភ័យមធ្យម | | |
| ២.២ | តើគម្រោងនេះត្រូវការកម្លាំងពលកម្មពីខាងក្រៅតំបន់គម្រោង(លើស១០នាក់)ដែលត្រូវរស់នៅក្នុងតំបន់គម្រោងក្នុងអំឡុងពេលអនុវត្តគម្រោង (ឧទាហរណ៍ក្រុមជាងសំណង់)? | | ហានិភ័យមធ្យម | | |
| ២.៣ | តើគម្រោងនេះតម្រូវឱ្យមនុស្សធ្វើការងារដែលមានគ្រោះថ្នាក់ខ្លាំង ដែលពួកគេមិនធ្លាប់ធ្វើ (ឧ.ការងារសំណង់) | | ហានិភ័យមធ្យម | | |
| ២.៤ | សម្រាប់គម្រោងដែលទទួលមូលនិធិ GCF៖ តើមានមូលហេតុណាផ្សេងដែលគម្រោងនេះអាចបង្កឱ្យមានហានិភ័យពាក់ព័ន្ធនឹងសេចក្តីណែនាំរបស់ GCF (ដូចបានរៀបរាប់ខាងលើ) ដែរឬទេ? | | ហានិភ័យខ្ពស់ ឬមធ្យម | | |

## យុទ្ធសាស្ត្រទី៣៖ ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងការបំពុល

| ការកាត់បន្ថយហានិភ័យលើការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងការបំពុលត្រូវយកចិត្តទុកដាក់លើ៖ |
|---|
| ក. ជៀសវាងការបញ្ចេញសារធាតុបំពុលខ្យល់ ទឹកនិងដីធ្លី ឬប្រសិនមិនអាចជៀសបាន ត្រូវកាត់បន្ថយនិង/ឬត្រូវគ្រប់គ្រងការបំពុលផ្សេងៗដោយសារការអនុវត្តគម្រោង។<br>ខ. ជៀសវាងការបង្កើតសំណល់ (ទាំងសំណល់បង្កគ្រោះថ្នាក់ និងមិនបង្កគ្រោះថ្នាក់) ឬប្រសិនមិនអាចជៀសបានត្រូវកាត់បន្ថយសំណល់ក្នុងកម្រិតតិចបំផុត ហើយត្រូវបញ្ចេញចោលឱ្យបានត្រឹមត្រូវ ។<br>គ. ត្រូវជំនួសវត្ថុធាតុដើមដែលមានគ្រោះថ្នាក់ខ្លាំងជាមួយនឹងសារធាតុដែលមានសុវត្ថិភាពជាងនេះ ហើយប្រសិនអាចធ្វើទៅបាន ត្រូវចៀសវាងការផលិត ការធ្វើពាណិជ្ជកម្ម និងការប្រើប្រាស់សារធាតុគីមីនិងវត្ថុធាតុដើមដែលមានគ្រោះថ្នាក់តាមការហាមឃាត់ ឬការបញ្ឈប់មិនឱ្យប្រើប្រាស់ជាអន្តរជាតិ ។<br>ឃ. ប្រើវិធីសាស្ត្រគ្រប់គ្រងសត្វចង្រៃ និងវិធានការផ្សេងៗទៀតរួមគ្នាដើម្បីកាត់បន្ថយហានិភ័យនៃការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត។<br>ង. ប្រើប្រាស់ធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពរួមទាំងថាមពលខ្យល់ និងទឹក។<br>ច. គណនាការបំភាយឧស្ម័នផ្ទះកញ្ចក់ (GHG) ប្រចាំឆ្នាំ សម្រាប់គម្រោងទាំងអស់ គឺរំពឹងថានឹងបញ្ចេញឧស្ម័នកាបូនិច ឬកាបូនឌីអុកស៊ីត(CO2) លើសចំនួន២៥០០០តោន។<br>ឆ. ត្រូវខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ (GHG)។ |

## ការសាកល្បងសំណួរសម្រាប់ហានិភ័យអំពីប្រសិទ្ធភាពធនធាន និងការគ្រប់គ្រងការបំពុល

| ល.រ | សំណួរ | មាន/អត់ | ហានិភ័យប្រសិនមាន | កម្រិតហានិភ័យ | មតិយោបល់ |
|---|---|---|---|---|---|
| ៣.១ | តើជាគម្រោងសាងសង់/តម្លើងរោងចក្រឧស្សាហកម្មឬកសិឧស្សាហកម្មដែលមានកម្មករលើសពី ២០នាក់ដែរឬទេ? | | ហានិភ័យខ្ពស់ | | |
| ៣.២ | តើជាគម្រោងសាងសង់/ការតម្លើងរោងចក្រឧស្សាហកម្មខ្នាតតូចឬកន្លែងកែច្នៃកសិផលដែលប្រើប្រាស់ឋាមពលលើស១០០kVA / ១១០hp? | | ហានិភ័យមធ្យម | | |
| ៣.៣ | តើគម្រោងនឹងតម្លើងជាអចិន្ត្រៃយ៍នូវឧបករណ៍ដែលប្រើប្រាស់សារធាតុគីមីដែរឬទេ? | | ហានិភ័យមធ្យម | | |
| ៣.៤ | តើជាគម្រោងដែលបង្កើតឱ្យមានសំណល់រឹងដែលមិនងាយរលាយដែរឬទេ? | | ហានិភ័យមធ្យម | | |

| | | | | | |
|---|---|---|---|---|---|
| ៣.៥ | តើជាគម្រោងដែលបញ្ចេញទឹកមានជាតិពុលដែរឬទេ? | | ហានិភ័យមធ្យម | | |
| ៣.៦ | តើជាគម្រោង ដែលនឹងបង្កើនការប្រើប្រាស់សារជាតុគីមីកសិកម្មដែរឬទេ? | | ហានិភ័យមធ្យម | | |
| ៣.៧ | តើជាគម្រោងដែលផលិត ឬដឹកជញ្ជូនសារជាតុគីមីបង្កគ្រោះថ្នាក់ដែរឬទេ? | | ហានិភ័យខ្ពស់ | | |
| ៣.៨ | តើគម្រោងនេះបង្កើនការបូមទឹកក្រោមដីលើសពី១០ម៉ែត្រគូបក្នុងថ្ងៃ ដោយយកពីកន្លែងតែមួយ? | | ហានិភ័យមធ្យម | | |
| ៣.៩ | តើគម្រោងនេះនឹងបូមយកទឹកច្រើនជាង១០%ពីក្នុងស្ទឹងឬព្រែកដែរឬទេ? | | ហានិភ័យមធ្យម | | |
| ៣.១០ | សម្រាប់គម្រោងដែលទទួលមូលនិធិ GCF៖ តើមានមូលហេតុណាផ្សេងដែលគម្រោងនេះអាចបង្កឱ្យមានហានិភ័យពាក់ព័ន្ធនឹងការសេចក្តីណែនាំរបស់ GCF ក្នុងការកាត់បន្ថយហានិភ័យតាមស្តង់ដាបំពេញការងារប្រភេទ៣(ដូចបានរៀបរាប់ខាងលើ) ដែរឬទេ? | | ហានិភ័យមធ្យម | | |

**យុទ្ធសាស្ត្រទី៤៖ សុខភាព សុវត្ថិភាព និងសុខុមាលភាពសហគមន៍**

| ការកាត់បន្ថយហានិភ័យលើសុខភាព សុវត្ថិភាព និងសុខុមាលភាពសហគមន៍ត្រូវយកចិត្តទុកដាក់លើ៖ |
|---|
| ក. វាយតម្លៃ និងចៀសវាងផលប៉ះពាល់អវិជ្ជមានទៅលើសុខភាព និងសុវត្ថិភាពរបស់សហគមន៍ដែលរងផលប៉ះពាល់របស់គម្រោង។ |
| ខ. វាយតម្លៃ និងចៀសវាងផលប៉ះពាល់លើគម្រោងប្រព័ន្ធអេកូឡូស៊ី (ឧ. ការបាត់បង់តំបន់ទ្រនាប់ដូចជាព្រៃកោងកាង ឬធនធានដូចជាទឹកសាប) ដែលសហគមន៍អាស្រ័យផល។ |
| គ. ចៀសវាង ឬកាត់បន្ថយជាអប្បបរមា ភាពងាយបង្កជំងឺ បណ្តាលពីការបោះចោលសំណល់គ្រោះថ្នាក់ការយកចិត្តទុកដាក់ចំពោះក្រុមជនងាយរងគ្រោះ។ |
| ឃ. វាយតម្លៃហានិភ័យអំពីសុវត្ថិភាពរបស់គម្រោងចំពោះសហគមន៍មូលដ្ឋាននិងបង្កើតជាប្រព័ន្ធមួយដើម្បីឆ្លើយតបទៅនឹងស្ថានភាពគ្រាអាសន្ន (រួមទាំងគ្រោះថ្នាក់ពីគម្រោងនិងគ្រោះថ្នាក់ធម្មជាតិ)។ |
| ង. វាយតម្លៃនិងកាត់បន្ថយហានិភ័យដែលបង្កឡើងដោយការគ្រប់គ្រងសន្តិសុខរបស់គម្រោង ដូចជាការប្រើប្រាស់សន្តិសុខឯកជន ប៉ូលីស ឬបុគ្គលិកយោធា។ |

ច. ស៊ើបអង្កេតរាល់ការចោទប្រកាន់អំពីអំពើខុសច្បាប់ឬអំពើរំលោភបំពានរបស់បុគ្គលិកសន្តិសុខ ចាត់វិធានការ (ឬ ជំរុញឱ្យភាគីពាក់ព័ន្ធដើម្បីចាត់វិធានការ) ដើម្បីទប់ស្កាត់ការតបតណាមួយ និងរាយការណ៍អំពើខុសច្បាប់ និងអំពើរំលោភបំពានដល់អាជ្ញាធរសាធារណៈ។

## សំណួរត្រួតពិនិត្យលើហានិភ័យសុខភាព សុវត្ថិភាព និងសុខុមាលភាពសហគមន៍

| ល.រ | សំណួរ | មាន/ អត់ | ហានិភ័យ ប្រសិនមាន | កម្រិត ហានិភ័យ | មតិយោបល់ |
|---|---|---|---|---|---|
| ៤.១ | តើគម្រោងនេះនឹងបង្កគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋដោយគ្រោះធម្មជាតិដូចជាទឹកជំនន់ ខ្យល់ព្យុះជាដើម (ឧ.គ្រោះកើតឡើងដោយសារតែប្រជាជនផ្លាស់ទីលំនៅឬទៅធ្វើការក្នុងតំបន់ងាយរងគ្រោះ)? | | ហានិភ័យខ្ពស់ | | |
| ៤.២ | តើគម្រោងនេះនឹងធ្វើឱ្យប្រជាពលរដ្ឋធ្វើការងារណាដែលមានគ្រោះថ្នាក់ដែលពួកគេមិនដែលធ្វើ? | | ហានិភ័យ មធ្យម | | |
| ៤.៣ | តើគម្រោងនេះនឹងផលិតម្ហូបអាហារដែលអាចបង្កគ្រោះថ្នាក់ដល់សុខភាពដោយសារមិនបានអនុវត្តតាមស្តង់ដាអនាម័យដែរឬទេ? | | ហានិភ័យ មធ្យម | | |
| ៤.៤ | តើគម្រោងនេះនឹងបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពឬសុវត្ថិភាពដល់ប្រជាជនក្នុងមូលដ្ឋានដែរឬទេ? | | ហានិភ័យ មធ្យម | | |
| ៤.៥ | តើគម្រោងនេះធ្វើឱ្យកើនឡើងចរាចរតាមផ្លូវដែរ ឬទេ? | | ហានិភ័យ មធ្យម | | |
| ៤.៦ | តើគម្រោងនេះនឹងបង្កើនឱ្យការប្រើប្រាស់កាំភ្លើងដែរ ឬទេ? | | ហានិភ័យ មធ្យម | | |
| ៤.៧ | តើគម្រោងនេះនឹងតម្រូវឱ្យជួលភ្នាក់ងារសន្តិសុខដែលអាចមានជម្លោះជាមួយសហគមន៍មូលដ្ឋានដែរ ឬទេ? | | ហានិភ័យ មធ្យម | | |
| ៤.៨ | សម្រាប់គម្រោងដែលទទួលមូលនិធិ GCF៖ តើមានមូលហេតុណាផ្សេងដែលគម្រោងនេះអាចបង្កឱ្យមានហានិភ័យពាក់ព័ន្ធនឹងការសេចក្តីណែនាំរបស់ GCF ក្នុងការកាត់បន្ថយហានិភ័យតាមស្តង់ដាបំពេញ | | ហានិភ័យខ្ពស់ ឬមធ្យម | | |

| ល.រ | សំណួរ | មាន/អត់ | ហានិភ័យប្រសិនមាន | កម្រិតហានិភ័យ | មតិយោបល់ |
|---|---|---|---|---|---|
| | ការងារប្រភេទ៤(ដូចបានរៀបរាប់ខាងលើ) ដែរឬទេ? | | | | |

## យុទ្ធសាស្ត្រទី៥÷ លទ្ធកម្មដីធ្លី និងការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត

**ការបន្ធូរបន្ថយហានិភ័យក្នុងការធ្វើលទ្ធកម្មដីធ្លី និងការតាំងលំនៅដោយមិនស្ម័គ្រចិត្តត្រូវផ្តោតការយកចិត្តទុកដាក់លើ៖**

ក. ជៀសវាងការបណ្តេញចេញដោយបង្ខំ រួមទាំងការបេង្ខិតបង្ខំ និងការនិយាយបន្ថែមបញ្ហាផ្សេងៗដល់សហគមន៍។
ខ. ជៀសវាងនិង / ឬកាត់បន្ថយការផ្លាស់ទីលំនៅ (ផ្លាស់ប្រជាជនចេញពីដីដែលពួកគេរស់នៅ) និងការផ្លាស់ប្តូរមូលដ្ឋានសេដ្ឋកិច្ច (ដូចជាកំហិតការចូលប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិរបស់ប្រជាជន)។
គ. ប្រាស្រ័យទាក់ទងជាមួយសហគមន៍ដែលរងផលប៉ះពាល់ក្នុងការផ្លាស់ទីលំនៅថ្មី ដូចជាតាមរយៈយន្តការបណ្តឹងតវ៉ាដែលធ្វើតាំងពីដំណាក់កាលដំបូងនៃការរៀបចំគម្រោង។
ឃ. ផ្តល់ឱ្យប្រជាជនដែលផ្លាស់ទីលំនៅទាំងអស់នូវសំណងដោយយុត្តិធម៌និងសមធម៌ ដូចជាដីធ្លី ប្រាក់ឬសំណងជាសម្ភារៈដែលបាត់បង់ ក៏ដូចជាធ្វើឱ្យពួកគាត់អាចប្រើប្រាស់ធនធានធម្មជាតិឡើងវិញ។
ង. កែលម្អ ឬស្តារឡើងវិញនូវជីវភាពរស់នៅរបស់ប្រជាជនទាំងនោះដែលត្រូវផ្លាស់ទីលំនៅ។
ច. ចំពោះអ្នកដែលមានសិទ្ធិស្របច្បាប់លើដីធ្លី ត្រូវផ្តល់ជម្រើសក្នុងការទទួលយកទ្រព្យសម្បត្តិដែលមានតម្លៃស្មើ ឬខ្ពស់ជាង និងសិទ្ធិកាន់កាប់ទ្រព្យនោះ (ក្នុងករណីមានដី ត្រូវផ្តល់សំណងជាសាច់ប្រាក់)។
ឆ. សម្រាប់ប្រជាពលរដ្ឋដែលមិនមានសិទ្ធិកាន់កាប់ដីធ្លីជាផ្លូវការ ដែលទទួលស្គាល់ដោយរដ្ឋាភិបាល ត្រូវផ្តល់ជាលំនៅដ្ឋានឱ្យបានសមរម្យ ដោយមានសិទ្ធិកាន់កាប់ដីធ្លីប្រកបដោយសុវត្ថិភាព ព្រមទាំងផ្តល់សំណងចំពោះទ្រព្យសម្បត្តិដែលបាត់បង់ជាសំណង់ផ្សេងៗជាដើម។

### សំណួរត្រួតពិនិត្យលើហានិភ័យលទ្ធកម្មដីធ្លី និងតាំងទីលំនៅមិនស្ម័គ្រចិត្ត

| ល.រ | សំណួរ | មាន/អត់ | ហានិភ័យប្រសិនមាន | កម្រិតហានិភ័យ | មតិយោបល់ |
|---|---|---|---|---|---|
| ៥.១ | តើមានអនុគម្រោងណាមួយ តម្រូវឱ្យមានការផ្លាស់ប្តូរទីលំនៅលើសពី២០នាក់ដែរឬទេ? | | ហានិភ័យខ្ពស់ | | |
| ៥.២ | តើគម្រោងនេះ តម្រូវឱ្យមានការផ្លាស់ប្តូរទីលំនៅតិចជាង២០នាក់ដែរឬទេ? | | ហានិភ័យមធ្យម | | |

| | | | | | |
|---|---|---|---|---|---|
| ៥.៣ | តើគម្រោងនេះ ធ្វើឱ្យគ្រួសារណាបាត់បង់សិទ្ធិកាន់កាប់ឬសិទ្ធិប្រើប្រាស់ដីដែលគាត់បានរកចំណូលលើស១០% នៃប្រាក់ចំណូលរបស់គ្រួសារ? | | ហានិភ័យខ្ពស់ | | |
| ៥.៤ | តើគម្រោងនេះ ធ្វើឱ្យគ្រួសារណាបាត់បង់សិទ្ធិកាន់កាប់ឬសិទ្ធិប្រើប្រាស់ដីធ្លីដែលគាត់បានរកចំណូលតិចជាង១០% នៃប្រាក់ចំណូលរបស់គ្រួសារ? | | ហានិភ័យមធ្យម | | |
| ៥.៥ | តើគម្រោងនេះតម្រូវឱ្យផ្លាស់ប្តូរ ឬវាយចោលសំណង់ដែលមានស្រាប់ ដែរឬទេ? | | ហានិភ័យមធ្យម | | |
| ៥.៦ | សម្រាប់គម្រោងដែលទទួលមូលនិធិ GCF៖ តើមានមូលហេតុណាផ្សេងដែលគម្រោងនេះអាចបង្កឱ្យមានហានិភ័យពាក់ព័ន្ធនឹងការសេចក្តីណែនាំរបស់ GCF ក្នុងការកាត់បន្ថយហានិភ័យលើលទ្ធកម្មដីធ្លី និងការតាំងទីលំនៅដោយបង្ខំ(ដូចបានរៀបរាប់ខាងលើ) ដែរឬទេ? | | ហានិភ័យខ្ពស់ឬមធ្យម | | |

## យុទ្ធសាស្ត្រទី៦÷ ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតប្រកបដោយចីរភាព

**ការកាត់បន្ថយហានិភ័យចំពោះការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតប្រកបដោយចីរភាព ត្រូវផ្តោតការយកចិត្តទុកដាក់លើ៖**

ក. វាយតម្លៃ និងជៀសវាងផលប៉ះពាល់ជីវចម្រុះនិងប្រព័ន្ធអេកូឡូស៊ី ប្រសិនមិនអាចជៀសវាងបាន ត្រូវចាត់វិធានការនានាដើម្បីកាត់បន្ថយនិងស្តារឡើងវិញផលប៉ះពាល់ណាមួយ។

ខ. អនុវត្តវិធានការការពារដល់គ្រប់តំបន់រងផលប៉ះពាល់ដែលមានតម្លៃជីវចម្រុះយ៉ាងសំខាន់ រួមទាំងជម្រកដែលត្រូវបានធ្វើឱ្យខូចខាតដោយសកម្មភាពរបស់មនុស្ស។

គ. វាយតម្លៃប្រព័ន្ធអេកូឡូស៊ីដែលបានរងផលប៉ះពាល់និង/ឬជៀសវាង និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានរួមទាំងផលប៉ះពាល់ដោយសារប្រភេទសត្វកម្រ។

ឃ. មិនត្រូវផ្លាស់ប្តូរឬកែប្រែ "ទីជម្រកធម្មជាតិ" ទេលុះត្រាតែ៖
- មិនមានជម្រើសសមស្របណាផ្សេងទៀត
- មានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធទាំងអស់
- ដាក់ចេញវិធានការបន្ធូរបន្ថយជៀសវាងមិនឱ្យមានការបាត់បង់ជីវចម្រុះ។

ង. មិនត្រូវអនុវត្តសកម្មភាពនៅក្នុង "ជម្រកសំខាន់" ឡើយលើកលែងតែ៖
- មិនមានជម្រើសផ្សេងទៀតក្រៅពីនេះ

- រាល់សកម្មភាពមិនបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានលើជីវចម្រុះនិងដំណើរការអេកូឡូស៊ី ឬបណ្តាលឱ្យថយចុះប្រភេទសត្វដែលជិតផុតពូជ
- មានផែនការត្រួតពិនិត្យត្រឹមត្រូវ។

ច. មិនត្រូវអនុវត្តសកម្មភាពក្នុងតំបន់ការពារដោយស្របច្បាប់ឬតំបន់ទទួលស្គាល់ជាអន្តរជាតិឡើយលើកលែង៖
- សកម្មភាពនេះត្រូវបានអនុញ្ញាតដោយស្របច្បាប់
- ការចូលរួមរបស់ភាគីពាក់ព័ន្ធត្រូវបានអនុវត្តត្រឹមត្រូវ
- មានការយកចិត្តទុកដាក់អនុវត្តវិធានការនានា ដើម្បីបង្កើនការអភិរក្សនៅក្នុងតំបន់នេះ។

ឆ. ធានាថារាល់សកម្មភាពដែលពាក់ព័ន្ធនឹងធនធានធម្មជាតិមានជីវិត( ឧ. ព្រៃឈើ កសិកម្ម) ត្រូវបានគោរពតាមស្តង់ដារជាតិ ស្តង់ដារតំបន់ឬស្តង់ដារសកលក្នុងការគ្រប់គ្រងដោយចីរភាព។

ជ. ត្រួតពិនិត្យលើខ្សែសង្វាក់ផ្គត់ផ្គង់របស់ស្ថាប័ននានាដើម្បីធានាថារាល់សកម្មភាពមិនបណ្តាលឱ្យមានការផ្លាស់ប្តូរជម្រកធម្មជាតិរបស់ពពួកសត្វ និងរុក្ខជាតិ។

## សំណួរត្រួតពិនិត្យលើហានិភ័យការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតប្រកបដោយចីរភាព

| ល.រ | សំណួរ | មាន/អត់ | ហានិភ័យប្រសិនមាន | កម្រិតហានិភ័យ | មតិយោបល់ |
|---|---|---|---|---|---|
| ៦.១ | តើមានសកម្មភាពណាមួយរបស់គម្រោង ស្ថិតនៅក្នុងតំបន់ការពារ ( ឧ. ឧទ្យានជាតិ ជម្រកសត្វព្រៃជាដើម) ឬក៏តំបន់ដែលមានសារៈសំខាន់សម្រាប់ការអភិរក្សជីវចម្រុះរបស់ជាតិឬអន្តរជាតិ? | | ហានិភ័យខ្ពស់ | | |
| ៦.២ | តើគម្រោងនេះ ត្រូវប្រើប្រាស់ដីព្រៃឈើធម្មជាតិលើសពី៥០ហិកតាដើម្បីការងារសាងសង់ឬការងារកសិកម្មដែរឬទេ? | | ហានិភ័យខ្ពស់ | | |
| ៦.៣ | តើគម្រោង តម្រូវឱ្យបង្ហូរទឹកចេញពីតំបន់ដីសើមធម្មជាតិលើសពី៥៩ហិកតាដែរឬទេ? | | ហានិភ័យខ្ពស់ | | |
| ៦.៤ | តើគម្រោងនេះនឹងបណ្តាលឱ្យមានការបំលែងព្រៃធម្មជាតិឬដីសើមតិចជាង៥០ហ.ត យកទៅប្រើប្រាស់ក្នុងគោលដៅផ្សេងដែរឬទេ? | | ហានិភ័យមធ្យម | | |

| ល.រ | សំណួរ | មាន/អត់ | ហានិភ័យប្រសិនមាន | កម្រិតហានិភ័យ | មតិយោបល់ |
|---|---|---|---|---|---|
| ៦.៥ | តើគម្រោងនេះជាការធ្វើកសិដ្ឋានដំណាំទំហំលើសពី៥០០ហិកតា ហើយដែលដីនេះមិនមានការដាំដុះដំណាំនាបច្ចុប្បន្នទេ? | | ហានិភ័យខ្ពស់ | | |
| ៦.៦ | តើគម្រោងនេះជាការធ្វើកសិដ្ឋានដំណាំទំហំតិចជាងពី៥០០ហិកតា ហើយដែលដីនេះមិនមានការដាំដុះដំណាំនាបច្ចុប្បន្នទេ? | | ហានិភ័យមធ្យម | | |
| ៦.៧ | តើគម្រោងបង្កើនការប្រើប្រាស់ធនធានព្រៃក្រៅពីឈើដែរឬទេ? | | ហានិភ័យមធ្យម | | |
| ៦.៨ | តើគម្រោងនេះនាំឱ្យមានការនេសាទត្រីកាន់តែកើនឡើងដែរឬទេ? | | ហានិភ័យមធ្យម | | |
| ៦.៩ | តើគម្រោង ត្រូវប្រើប្រាស់ព្រៃឈើធ្វើពាណិជ្ជកម្មដែលមានទំហំលើសពី៥០០ហិកតាដែរឬទេ? | | ហានិភ័យខ្ពស់ | | |
| ៦.១០ | តើគម្រោង ត្រូវប្រើប្រាស់ព្រៃឈើធ្វើពាណិជ្ជកម្មដែលមានទំហំតិចជាង៥០០ហិកតាដែរឬទេ? | | ហានិភ័យមធ្យម | | |
| ៦.១១ | តើគម្រោងផ្លាស់ប្តូររបៀបដាំដុះដំណាំលើដីលើសពី៥០០ហិកតាដែរឬទេ? | | ហានិភ័យមធ្យម | | |
| ៦.១២ | តើគម្រោងនេះបង្កើនការចិញ្ចឹមសត្វលើដីទំហំលើសពី៥០០ហិកតាដែរឬទេ? | | ហានិភ័យមធ្យម | | |
| ៦.១៣ | តើគម្រោងនេះសម្រាប់ការចិញ្ចឹមត្រី(ទំហំលើសពី២៥ហ.ត)ដែរឬទេ? | | ហានិភ័យខ្ពស់ | | |
| ៦.១៤ | តើគម្រោងនេះសម្រាប់ការចិញ្ចឹមត្រី(ទំហំតិចជាង២៥ហ.ត)ដែរឬទេ? | | ហានិភ័យមធ្យម | | |
| ៦.១៥ | តើគម្រោង ត្រូវការប្រើប្រាស់ពូជសត្វឬដំណាំកែច្នៃហ្សែនដែរឬទេ? | | ហានិភ័យខ្ពស់ | | |
| ៦.១៦ | តើគម្រោងនេះអាចនាំឱ្យមានហានិភ័យនៃនាំចូលប្រភេទសត្វ រុក្ខជាតិថ្មីៗ (ដូចរុក្ខជាតិឬសត្វព្រៃដែលមិនធ្លាប់មាននៅក្នុងតំបន់នេះពីមុនទេ)? | | ហានិភ័យខ្ពស់ | | |

| ល.រ | សំណួរ | មាន/អត់ | ហានិភ័យប្រសិនមាន | កម្រិតហានិភ័យ | មតិយោបល់ |
|---|---|---|---|---|---|
| ៦.១៧ | តើគម្រោងនេះ មានបញ្ចូលសកម្មភាពអភិរក្សដីធ្លីនិងគុណភាពដីដែរឬទេ? | | ហានិភ័យមធ្យម | | |
| ៦.១៨ | តើគម្រោងនេះមានបញ្ចូលសកម្មភាពគ្រប់គ្រងតំបន់ផ្ទៃរងទឹកភ្លៀងដែរឬទេ? | | ហានិភ័យមធ្យម | | |
| ៦.១៩ | សម្រាប់គម្រោងដែលទទួលមូលនិធិ GCF៖ តើមានមូលហេតុណាផ្សេងដែលគម្រោងនេះអាចបង្កឱ្យមានហានិភ័យពាក់ព័ន្ធនឹងការសេចក្តីណែនាំរបស់ GCF ក្នុងការកាត់បន្ថយហានិភ័យតាមស្តង់ដាបំពេញការងារប្រភេទ៦(ដូចបានរៀបរាប់ខាងលើ) ដែរឬទេ? | | ហានិភ័យខ្ពស់ឬមធ្យម | | |

**យុទ្ធសាស្ត្រទី៧៖ ជនជាតិដើមភាគតិច**

| **ការកាត់បន្ថយហានិភ័យលើជនជាតិដើមភាគតិច ត្រូវយកចិត្តទុកដាក់លើ៖** |
|---|
| ក. កំណត់អត្តសញ្ញាណជនជាតិដើមភាគតិចដែលអាចរងផលប៉ះពាល់ពីគម្រោងនិងស្ថានភាពនៃផលប៉ះពាល់នោះ (បញ្ហាសេដ្ឋកិច្ច សង្គម និងបញ្ហាបរិស្ថានជាដើម)។<br>ខ. ជៀសវាងផលប៉ះពាល់អវិជ្ជមានលើជនជាតិដើមភាគតិចតាមលទ្ធផលដែលអាចទទួលយកបាន ឬកាត់បន្ថយជាអប្បបរមា ឬស្តារឡើងវិញឬទូទាត់ជាសំណងដោយសារផលប៉ះពាល់ចំពោះប្រពៃណីរបស់ជនជាតិដើមភាគតិច។<br>គ. រៀបចំវិធានការទាំងអស់ដែលទាក់ទងទៅនឹងជនជាតិដើមភាគតិចដោយមានការពិគ្រោះយោបល់និងការចូលរួមព័ត៌មានពេញលេញក្នុងពេញមួយជីវិតរបស់គម្រោង។<br>ឃ. មិនត្រូវបង្កើតគម្រោងលើដីធ្លីដែលជាកម្មសិទ្ធិជាប្រពៃណីឬប្រើប្រាស់ដោយជនជាតិដើមភាគតិចឡើយ លុះត្រាតែមានការវាយតម្លៃហានិភ័យត្រូវឱ្យបានហ្មត់ចត់ ហើយសហគមន៍ជនជាតិដើមភាគតិចត្រូវបានជូនដំណឹងពីសិទ្ធិរបស់ពួកគេ ព្រមទាំងធានាថាជនជាតិដើមភាគតិចទាំងនោះ នៅតែបន្តទទួលសិទ្ធិប្រើប្រាស់ធនធាន បើសិនជាអាចធ្វើបាន ត្រូវផ្តល់សំណងសមរម្យហើយ ហើយត្រូវចែករំលែកអត្ថប្រយោជន៍នៃគម្រោងជូនដោយយុត្តិធម៌និងសមធម៌។<br>ង. មិនត្រូវផ្លាស់ទីលំនៅជនជាតិដើមភាគតិចពីដីធ្លីឬធនធានធម្មជាតិដែលពួកគេធ្លាប់កាន់កាប់ ឬប្រើប្រាស់តាមបែបប្រពៃណីឡើយ លើកលែងតែមានការយល់ព្រមជាមុនដោយគ្មានការបង្ខិតបង្ខំ។<br>ច. មិនត្រូវបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើមរតកវប្បធម៌ពួកគេឡើយ លុះត្រាតែមានការយល់ព្រមជាមុនដោយគ្មានការបង្ខិតបង្ខំ។ |

| |
|---|
| ធ. មិនត្រូវប្រើប្រាស់ចំណេះដឹងជាប្រពៃណី ឬមរតកវប្បធម៌របស់ជនជាតិដើមភាគតិចសម្រាប់គោលបំណងពាណិជ្ជកម្មទេដោយគ្មានការព្រមព្រៀងជាមុនដោយគ្មានការបង្ខិតបង្ខំ ហើយត្រូវរៀបចំការចែករំលែកអត្ថប្រយោជន៍ឱ្យបានយុត្តធម៌ត្រឹមត្រូវ។ |

## សំណួរត្រួតពិនិត្យហានិភ័យចំពោះជនជាតិដើមភាគតិច

| ល.រ | សំណួរ | មាន/អត់ | ហានិភ័យប្រសិនមាន | កម្រិតហានិភ័យ | មតិយោបល់ |
|---|---|---|---|---|---|
| ៧.១ | តើ គម្រោងនេះធ្វើឱ្យមានការអភិវឌ្ឍដីធ្លីដែលត្រូវបានប្រើប្រាស់បែបប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិចដែរឬទេ ? | | ហានិភ័យខ្ពស់ | | |
| ៧.២ | តើគម្រោងនេះ ប្រើប្រាស់មរតកវប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិចដែរឬទេ( ឧ. សម្រាប់ ទេសចរណ៍ ) | | ហានិភ័យខ្ពស់ | | |
| ៧.៣ | តើតំបន់គោលដៅរបស់គម្រោងមានបញ្ចូលនូវទីកន្លែងដែលមានជនជាតិដើមភាគតិចរស់នៅលើសពី៣០%ដែរឬទេ ? | | ហានិភ័យមធ្យម | | |
| ៧.៤ | តើគម្រោងនេះមានផលប៉ះពាល់អវិជ្ជមានទៅលើសហគមន៍ជនជាតិដើមភាគតិចដែរឬទេ ( ឧ. ប្រពៃណី វប្បធ៌ម ជីវភាពរស់នៅ ឬរបៀបប្រើប្រាស់ដីធ្លីបែបប្រពៃណី ) ? | | ហានិភ័យមធ្យម | | |
| ៧.៥ | សម្រាប់គម្រោងដែលទទួលមូលនិធិGCF៖ តើមានមូលហេតុណាផ្សេងដែលគម្រោងនេះអាចបង្កឱ្យមានហានិភ័យពាក់ព័ន្ធនឹងការសេចក្តីណែនាំរបស់ GCF ក្នុងការកាត់បន្ថយហានិភ័យចំពោះជនជាតិដើមភាគតិច( ដូចបានរៀបរាប់ខាងលើ ) ដែរឬទេ ? | | ហានិភ័យខ្ពស់ ឬមធ្យម | | |

## យុទ្ធសាស្ត្រទី៨÷ បេតិកភណ្ឌវប្បធម៌

| ការបន្ធូរបន្ថយហានិភ័យប៉ះពាល់ដល់បេតិកភណ្ឌវប្បធម៌ ត្រូវយកចិត្តទុកដាក់លើ៖ |
|---|
| ក. កំណត់អត្តសញ្ញាណ និងជៀសវាងផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរលើបេតិកភណ្ឌវប្បធម៌រូបីយ៍ (ដូចជាទីតាំងបុរាណវិទ្យាឬប្រវត្តិសាស្ត្រ) ឬតំបន់ធម្មជាតិពិសេសដែលតំណាងឬមានតម្លៃផ្នែកវប្បធម៌ (ដូចជាសិលាសម្រាប់គោរពបូជា ឬទឹកជ្រោះ) ។ |
| ខ. ពិគ្រោះយោបល់ជាមួយសហគមន៍ដែលរងផលប៉ះពាល់និងភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធដើម្បីកំណត់អត្តសញ្ញាណបេតិកភណ្ឌវប្បធម៌ដែលសំខាន់។ |
| គ. បង្កើតប្រព័ន្ធសម្រាប់ការពារបេតិកភ័ណ្ឌវប្បធម៌ដែលត្រូវបានរកឃើញក្នុងអំឡុងពេលអនុវត្តគម្រោង (ដែលហៅថានីតិវិធីគ្រប់គ្រងដោយការរកឃើញដោយចៃដន្យ) ។ |
| ឃ. អនុញ្ញាតឱ្យសហគមន៍ចូលទៅកាន់តំបន់បេតិកភណ្ឌវប្បធម៌ដែលស្ថិតនៅក្នុងតំបន់ទីតាំងគម្រោង។ |
| ង. មិនត្រូវយកចេញ កែប្រែផ្លាស់ប្តូរទីតាំង ឬបំផ្លាញបេតិកភណ្ឌវប្បធម៌ទាំងនោះជាដាច់ខាត (ដូចជាតំបន់បេតិកភណ្ឌដែលត្រូវបានទទួលស្គាល់ជាលក្ខណៈអន្តរជាតិឬការពារដោយច្បាប់) លើកលែងតែក្នុងករណីពិសេសណាមួយ ប៉ុន្តែត្រូវតែសហការជាមួយសហគមន៍ដែលរងផលប៉ះពាល់។ |
| ច. ប្រើប្រាស់បេតិកភណ្ឌវប្បធម៌អរូបីយ៍ (ដូចជាចំណេះដឹង ការច្នៃប្រឌិតឬការអនុវត្តផ្សេងៗ) សម្រាប់គោលបំណងពាណិជ្ជកម្មបានលុះត្រាតែមានការសហការជាមួយសហគមន៍ដែលពាក់ព័ន្ធតែប៉ុណ្ណោះ។ |

## សំណួរត្រួតពិនិត្យហានិភ័យលើបេតិកភណ្ឌវប្បធម៌

| ល.រ | សំណួរ | មាន/ អត់ | ហានិភ័យ ប្រសិនមាន | កម្រិត ហានិភ័យ | មតិយោបល់ |
|---|---|---|---|---|---|
| ៨.១ | តើមានទីតាំងគម្រោងណាមួយស្ថិតនៅក្នុងកន្លែងបេតិកភណ្ឌវប្បធម៌រូបវ័ន្តឬអរូបវ័ន្តដែលមានសារៈសំខាន់សម្រាប់ជាតិឬអន្តរជាតិដែរឬទេ? | | ហានិភ័យខ្ពស់ | | |
| ៨.២ | តើសកម្មភាពរបស់គម្រោងនឹងមានផលប៉ះពាល់អវិជ្ជមានជាអចិន្ត្រៃយ៍ទៅលើបេតិកភ័ណ្ឌវប្បធម៌រូបវ័ន្តសំខាន់ៗណាមួយ (ឧ. ប្រាសាទឬសំណង់បូរាណជាដើម) | | ហានិភ័យខ្ពស់ | | |
| ៨.៣ | តើសកម្មភាពរបស់គម្រោងនឹងមានផលប៉ះពាល់អវិជ្ជមានជាអចិន្ត្រៃយ៍ទៅលើបេតិកភណ្ឌវប្បធម៌អរូបវ័ន្តសំខាន់ៗណាមួយ (ឧ. វប្បធម៌ប្រពៃណីនៅក្នុងមូលដ្ឋាននោះ)? | | ហានិភ័យខ្ពស់ | | |

| | | | | | |
|---|---|---|---|---|---|
| ៨.៤ | តើគម្រោងនេះមានផលប៉ះពាល់អវិជ្ជមានទោះកម្រិតតិចតួចក្តី ឬក្នុងរយៈពេលខ្លីក៏ដោយទៅលើបេតិកភណ្ឌវប្បធម៌រូបវ័ន្ត និងអរូបវ័ន្តដែរឬទេ? | | ហានិភ័យមធ្យម | | |
| ៨.៥ | សម្រាប់គម្រោងដែលទទួលមូលនិធិGCF៖ តើមានមូលហេតុណាផ្សេងដែលគម្រោងនេះអាចបង្កឱ្យមានហានិភ័យពាក់ព័ន្ធនឹងសេចក្តីណែនាំរបស់ GCF ក្នុងការកាត់បន្ថយហានិភ័យចំពោះបេតិកភណ្ឌវប្បធម៌(ដូចបានរៀបរាប់ខាងលើ) ដែរឬទេ? | | ហានិភ័យខ្ពស់ឬមធ្យម | | |

## ឧបសម្ព័ន្ធ២៖ ផែនការគ្រប់គ្រងផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គម

| ហានិភ័យ | វិធានការណ៍កាត់បន្ថយ | ការទទួលខុសត្រូវ | កាលបរិច្ឆេទ | សូចនាករសម្រាប់ការតាមដាន |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |